# អនុសញ្ញា
# ស្តីពី
# សិទ្ធិជនពិការ



DAC
ក្រុមប្រឹក្សាសកម្មភាពជនពិការ

Australian AID

# អារម្ភកថា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១ បានចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញា ទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ។ ដោយឡែកមាត្រា៧៤ ចែងថា រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពនិងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈក្នុងសង្គម ធនធាន ឬស្ថានភាពដទៃទៀតឡើយ។ ការប្រើប្រាស់សិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ មិនត្រូវឲ្យប៉ះពាល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើប្រាស់សិទ្ធិនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។ កម្ពុជា បានធ្វើសហមារណកម្មខ្លួនយ៉ាងពេញលេញទៅក្នុងប្រទេស អនុតំបន់ តំបន់ និងពិភពលោក។ លើបញ្ហាសិទ្ធិមនុស្ស កម្ពុជាបានក្លាយជារដ្ឋភាគីនៃធម្មនុញ្ញអង្គការសហប្រជាជាតិ រួមមាន៖

១). អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ នៅថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៨៣

២). កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌នៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ១៩៩២

៣). កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ១៩៩២

៤). អនុសញ្ញាបំបាត់រាល់ការរើសអើងប្រឆាំងនឹងស្ត្រីភេទនៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ១៩៩២

៥). អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តលើខ្លួនប្រាណឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប នៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ១៩៩២ និងពិធីសារបន្ថែមលើអនុសញ្ញានេះនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៧

៦). អនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែម នៅថ្ងៃទី ១៤ ខែវិច្ឆិកាឆ្នាំ១៩៩២

ធម្មនុញ្ញអង្គការសហប្រជាជាតិខាងលើ មានគោលបំណងជាចម្បងគឺការលើកស្ទួយសិទ្ធិសេរីភាព សមភាព និងសេចក្តីថ្លៃថ្នូរពីកំណើត លុបបំបាត់ការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា សេចក្តីថ្លៃថ្នូរ និងយុត្តិធម៌ទាំងអស់គ្នា។ ទោះបីមានធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ប្រកបដោយភាពលំអិតលើផ្លូវច្បាប់ គោលការណ៍ និងវិធាននានាក្តី ក៏ក្នុងពិភពលោកជនពិការនៅតែប្រឈមនឹងការរើសអើង ការរំលោភបំពានលើសិទ្ធិរបស់ពួកគេ និងឧបសគ្គផ្សេងៗជាច្រើនទៀតដែលជារនាំងមិនឲ្យពួកគេចូលរួមយ៉ាងពេញលេញក្នុងសកម្មភាពសង្គម។ ដោយមើលឃើញកត្តាប្រឈមនេះហើយទើបនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៦ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តសន្ធិសញ្ញាអន្តរជាតិថ្មីមួយ ដែលមានគោលបំណងជាពិសេស គឺការលើកស្ទួយ ការពារ និងធានាថាជនពិការទទួលបានដោយពេញលេញនូវសិទ្ធិមនុស្ស សេរីភាពជាសារវ័ន្ត គោរពសេចក្តីថ្លៃថ្នូរ ដែល មានពីកំណើតរបស់ពួកគេ។ អនុសញ្ញានេះបានទុករយៈមួយឆ្នាំ សម្រាប់ជាឱកាសដល់ប្រទេសលើពិភពលោកចុះហត្ថលេខា ហើយជាលទ្ធផលមានប្រទេសចំនួន ១៥៥ បានចុះហត្ថលេខាលើអនុសញ្ញា និង៩០ ប្រទេសបានចុះហត្ថលេខាលើពិធីសាស្រ្តបន្ថែម។ អនុសញ្ញានេះបានចូលជាធរមាន នៅថ្ងៃទី ៣ខែឧសភា ឆ្នាំ២០០៨។ គិតត្រឹម

ខែមករា ឆ្នាំ២០១៣ នេះមានប្រទេសចំនួន ១២៧ បានផ្តល់សច្ចាប័នរួមទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ និងប្រទេសចំនួន ៧៦ បានផ្តល់សច្ចាប័នលើពិធីសារបន្ថែម។

ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិជនពិការនេះ និងពិធិសារបន្ថែម នៅថ្ងៃទី ០១ ខែតុលា ឆ្នាំ២០០៧ ដោយឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ការចុះហត្ថលេខានេះជាចំណុចចាប់ផ្តើម ដើម្បីបើកផ្លូវឲ្យព្រះរាជាណាចក្រកម្ពុជាបានចាត់វិធានការបន្តក្នុងការផ្តល់ សច្ចាប័ន លើអនុសញ្ញានេះ។ ដើម្បីផ្តល់សច្ចាប័នបាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតក្រុមការងារមួយតាមលិខិតបង្គាប់ការលេខ១៧៨៧ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១១ ដែលមានសមាសភាពមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា គណៈកម្មការសិទ្ធិមុស្សកម្ពុជា ទីភ្នាក់ងារអភិវឌ្ឍ និងអង្គការដៃគូរពាក់ព័ន្ធនានា។ ក្រុមការងារនេះ មានភារកិច្ចប្រមូលរាល់ឯកសារពាក់ព័ន្ធ សរសេរសេចក្តីថ្លែងហេតុ និងពិនិត្យកែសម្រួលខ្លឹមសារនៃការបកប្រែមុននឹងដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ។ នៅថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១២ កិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបញ្ជូនឯកសារនៃអនុសញ្ញាជូនស្ថាប័ននីតិបញ្ញត្តិដើម្បីសុំការផ្តល់សច្ចាប័ន។ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២ រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជាបានបើកសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៤ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា បានសម្រេច ជាឯកច្ឆន្ទ យល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជារដ្ឋភាគីនៃអនុសញ្ញានេះ ដោយសម្លេង៨១ លើ៨១។ នៅថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ២០១២ ក្នុងសម័យប្រជុំពេញអង្គ ព្រឹទ្ធសភាបានសម្រេចយល់ព្រមជាឯកច្ឆ័ន្ទហើយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២។ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ទ្រង់បានឡាយព្រះហស្តលេខាលើច្បាប់អនុញ្ញាតឲ្យព្រះរាជាណាចក្រកម្ពុជាចូលជារដ្ឋភាគីពេញសិទ្ធិលើអនុសញ្ញានេះ តាមរយៈច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជារដ្ឋភាគីអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពីការ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានតម្កល់លិខិតតុបករណ៍ជូនគណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការ របស់អង្គការសហប្រជាជាតិ ទីក្រុងញូយ៉កហើយកម្ពុជាបានក្លាយជារដ្ឋភាគី ចាប់ពីថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៣ តទៅ។

សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ និងបងប្អូនជនពិការទាំងអស់ជាទីគោរពរាប់អាន មាត្រាទី៤៩ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ បានកំណត់ថា បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិ ទាក់ទងនឹងច្បាប់ស្តីពីកិច្ចការពារ និងលើកម្ពស់សិទ្ធិជនពិការ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីត្រូវយកមកអនុវត្តជាមួយនឹងច្បាប់ជាតិ។ ក្នុងករណីមានទំនាស់ជាមួយនឹងបទប្បញ្ញត្តិទាំងឡាយ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការបទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះត្រូវទុកជាបទប្បញ្ញត្តិគោល។ អនុសញ្ញានេះ បានបង្កើតឡើងដោយចែកចេញជា ៥០មាត្រា ដែលមាត្រាភាគច្រើនគឺស្របគ្នាទាំងស្រុងជាមួយនឹងច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម /០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩។ អ្វីដែលមានភាពលំអៀងខ្លះនោះ

គឺ និយមន័យស្តីពីពិការភាព ដោយច្បាប់ជាតិរបស់យើងផ្តោតជាសំខាន់លើ គំរូវេជ្ជសាស្ត្រ ហើយនិយមន័យនៃអនុសញ្ញានេះ មានន័យទូលំទូលាយ និងពិស្តារជាង។ បទប្បញ្ញត្តិនៃអនុសញ្ញានេះបានចែងលំអិតអំពីការអនុវត្តន៍ និងការឃ្លាំមើលថ្នាក់ជាតិ ការប្រមូលទិន្នន័យ ឬស្ថិតិ ការសរសេរបាយការណ៍ តួនាទីរបស់រដ្ឋភាគីក្នុងកិច្ចសហប្រតិបត្តិការ អន្តរជាតិ និងតួនាទីរបស់អង្គការសហប្រជាជាតិក្នុងការជួយប្រទេសដែលកំពុងអភិវឌ្ឍ។ អ្វីដែលបានកំណត់ ក្នុងអនុសញ្ញានេះពិតជាមានតម្រូវការ និងតម្លៃធំធេង ហើយវាក៏បានក្លាយជាកម្មវត្ថុនៃបញ្ហាប្រឈមសម្រាប់ប្រទេស ជាច្រើនដែលក្នុងនោះមាន ប្រទេសកម្ពុជាយើងដែរ។ ទោះបីយ៉ាងនេះក្តី កម្ពុជាមានបទពិសោធន៍គ្រប់គ្រាន់ និងការប្តេជ្ញាខ្ពស់ ពិតជាជម្នះបានគ្រប់ឧបសគ្គដើម្បីបំពេញកាតព្វកិច្ចមួយនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ប៉ុន្តែយើងពិតជាត្រូវការ ការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន ដៃគូអភិវឌ្ឍ អង្គការជាតិ និងអន្តរជាតិ និងជាពិសេសការណែនាំ និងអនុសាសន៍ជំនាញពីគណៈកម្មាការទទួលបន្ទុកសិទ្ធិជនពិការ ដើម្បីសម្រេចគ្រប់គោលដៅទាំងឡាយដែលមានចែងក្នុងគោលដៅនៃអនុសញ្ញានេះ។

អត្ថប្រយោជន៍នៃការផ្តល់សច្ចាប័ននៃអនុសញ្ញានេះគឺកម្ពុជាមានបទប្បញ្ញត្តិជាធរមាន មួយទៀតដើម្បីបំពេញបន្ថែមលើ ច្បាប់ជាតិដែលមានស្រាប់ ធ្វើសមាហរណកម្មវិស័យពិការភាពនៃព្រះរាជាណាចក្រកម្ពុជា ជាមួយសហគមន៍អន្តរជាតិ បង្កើនភាពជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍ រដ្ឋភាគីនៃអនុសញ្ញានេះ និងបង្កើនការផ្តល់សេវាដល់ជនពិការ និងការធ្វើសមាហរណកម្មជនពិការទៅក្នុងសង្គមដោយគ្មានឧបសគ្គរារាំង។

ក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ ខ្ញុំបាទសូមថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាជាតិ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ដែលជានិច្ចកាលសម្តេចទាំងបីតែងយកចិត្តទុកដាក់ គិតគូរពីទុក្ខលំបាកប្រជាពលរដ្ឋ ជាពិសេសបងប្អូនជនពិការកម្ពុជា ដោយបានជំរុញការអនុម័តនិងអនុវត្តច្បាប់សម្រាប់ជនពិការទាំងច្បាប់ជាតិនិងអន្តរជាតិ។

សូមក្រាបថ្វាយបង្គំ និងសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលបានឡាយព្រះហស្តលេខាឲ្យព្រះរាជាណាចក្រកម្ពុជាចូលជារដ្ឋភាគីនៃអនុសញ្ញានេះ។

សូមគោរពថ្វាយព្រះពរ និងជូនពរ ព្រះមហាក្សត្រ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិជាពិសេសបងប្អូន ជនពិការទាំងអស់ទទួលបាន សុខភាពល្អ ប្រាជ្ញាឈ្លាសវៃ និងជោគជ័យគ្រប់ភារកិច្ច។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

ព្រះរាជក្រម

នស/រកម/០៩១២/០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាន

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូល ជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ

**មាត្រា ១.-**

អនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក នាថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦ និងចូលជាធរមាននៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ និងដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខានាថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.១២០៩.៥៥៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ហត្ថលេខា

អ៊ិត សំហេង

លេខ:៨០៩ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១២

អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

**អង្គការសហប្រជាជាតិ**

**យោង:** C.N.725.2012.TREATIES-IV.15 (ជូនដំណឹងអំពីការរក្សាទុកឯកសារ)

**អនុសញ្ញាស្តីពីសិទ្ធិជនពិការ**

*ញូវយ៉ក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦*

**ប្រទេសកម្ពុជា: ការផ្តល់សច្ចាប័ន**

អគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងក្របខ័ណ្ឌកិច្ចការរក្សាឯកសារ ដែលទាក់ទងដូចខាងក្រោម៖

សកម្មភាពខាងលើចាប់មានប្រសិទ្ធភាពនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២

អនុសញ្ញានេះនឹងចូលជាធរមានចំពោះប្រទេសកម្ពុជាចាប់ពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៣ យោងតាមមាត្រា ៤៥ (២)ដែលចែងដូចខាងក្រោម៖

"ចំពោះរដ្ឋ ឬអង្គការសមាហរណកម្មថ្នាក់តំបន់នីមួយៗដែលនឹងផ្តល់សច្ចាប័ន បញ្ជាក់ជាផ្លូវការ ឬចូលជាសមាជិកនៃអនុសញ្ញានេះ ក្រោយពីការតម្កល់ទុកលិខិតុបករណ៍ទី២០នោះ អនុសញ្ញានេះត្រូវចូលជាធរមាននៅថ្ងៃទី៣០ ក្រោយពីការតម្កល់ទុកលិខិតុបករណ៍របស់ខ្លួន។"

ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២

ហត្ថលេខា

ប្រយ័ត្ន៖ ផ្នែកសេវាកម្មសន្ធិសញ្ញានៃក្រសួងការបរទេស និងអង្គការអន្តរជាតិដែលពាក់ព័ន្ធ។ រាល់ការជូនដំណឹងស្តីពីការរក្សាទុកឯកសារត្រូវបានចេញជាគំរូអេឡិចត្រូនិចតែប៉ុណ្ណោះ។ រាល់ការជូនដំណឹងស្តីពីការរក្សាទុកឯកសារត្រូវតែអាចរកបានដោយ បេសកកម្មអចិន្ត្រៃយ៍ក្នុងផ្នែកប្រមូលឯកសារសន្ធិសញ្ញានៃអង្គការសហប្រជាជាតិតាមអាសយដ្ឋានអ៊ីនធឺណេត http://treaties.un.org ក្នុងចំណងជើង "ជូនដំណឹងពីនេះទៀត បេសកកម្មអចិន្ត្រៃយ៍ រួមទាំងបុគ្គលដែលចាប់អារម្មណ៍ផ្សេងទៀត អាចចុះឈ្មោះក្នុងការទទួលបានលិខិត ជូនដំណឹងអំពីការរក្សាទុកឯកសារអំពីការរក្សាទុកឯកសារ"។ លើសដោយអ៊ីម៉ែលតាមរយៈ ផ្នែកសន្ធិសញ្ញា "សេវាកម្មចុះឈ្មោះស្វ័យប្រវត្តិ" ដែលក៏អាចរកបាននៅ http://treaties.un.org

POSTAL ADDRESS—ADRESSE POSTALE: UNITED NATIONS, N.Y. 10017
CABLE ADDRESS—ADRESSE TELEGRAPHIQUE: UNATIONS NEWYORK

Reference: C.N.725.2012.TREATIES-IV.15 (Depositary Notification)

CONVENTION ON THE RIGHTS OF PERSONS WITH DISABILITIES
NEW YORK, 13 DECEMBER 2006

CAMBODIA: RATIFICATION

The Secretary-General of the United Nations, acting in his capacity as depositary, communicates the following:

The above action was effected on 20 December 2012.

The Convention will enter into force for Cambodia on 19 January 2013 in accordance with its article 45 (2) which reads as follows:

"For each State or regional integration organization ratifying, formally confirming or acceding to the present Convention after the deposit of the twentieth such instrument, the Convention shall enter into force on the thirtieth day after the deposit of its own such instrument."

20 December 2012

Attention: Treaty Services of Ministries of Foreign Affairs and of international organizations concerned. Depositary notifications are issued in electronic format only. Depositary notifications are made available to the Permanent Missions to the United Nations in the United Nations Treaty Collection on the Internet at http://treaties.un.org, under "Depositary Notifications (CNs)". In addition, the Permanent Missions, as well as other interested individuals, can subscribe to receive depositary notifications by e-mail through the Treaty Section's "Automated Subscription Services", which is also available at http://treaties.un.org.

# បុព្វកថា

រដ្ឋភាគីនៃអនុសញ្ញានេះ ៖

ក- ដោយរំលឹកឡើងវិញពីគោលការណ៍ទាំងឡាយ ដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិដែលទទួលស្គាល់សេចក្តីថ្លៃថ្នូរ និងតម្លៃ និងសិទ្ធិស្មើគ្នាដែលមិនអាចលក់ដូរបានដែលមានពីកំណើតនៃសមាជិកគ្រប់រូបក្នុងសង្គមមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

ខ- ដោយទទួលស្គាល់ថា តាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស អង្គការសហប្រជាជាតិបានប្រកាស និងបានយល់ព្រមថា មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសិទ្ធិ និងសេរីភាពគ្រប់បែបយ៉ាង ដូចដែលមានចែងក្នុងសេចក្តីប្រកាសជាសកល និងក្នុងកតិកាសញ្ញាអន្តរជាតិទាំងនេះដោយគ្មានការបែងចែកនៃប្រភេទណាមួយឡើយ។

គ- ដោយគូសបញ្ជាក់ឡើងវិញថា សកលភាព ភាពមិនអាចបំបែកបាន ភាពពំនាក់អាស្រ័យគ្នា និងភាពទាក់ទងគ្នានៃសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ព្រមទាំងសេចក្តីត្រូវការរបស់ជនពិការត្រូវបានធានាយ៉ាងពេញលេញ ដោយគ្មានការរើសអើង។

ឃ- ដោយរំលឹកឡើងវិញ ពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ អនុសញ្ញា អន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការប្រកាន់ពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើ

ទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទារុណកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក អនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារសិទ្ធិរបស់កម្មករទេសន្តប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ខ្លួន។

ង- ដោយទទួលស្គាល់ថា ពិការភាពគឺជាទស្សនទានដែលមានការវិវត្ត ហើយពិការភាពកើតចេញពីអន្តរកម្មរវាងជនពិការ និងឧបសគ្គទាំងឡាយទាក់ទងទៅនឹងអាកប្ប-កិរិយា និងបរិយាកាសជុំវិញដែលរារាំងពួកគេមិនឲ្យចូលរួមក្នុងសង្គមបានពេញលេញ និងប្រកបដោយប្រសិទ្ធភាពដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។

ច- ដោយទទួលស្គាល់ពីសារៈសំខាន់នៃគោលការណ៍ និងសេចក្តីណែនាំពីគោលនយោបាយ ដែលមាននៅក្នុងកម្មវិធីសកម្មភាពពិភពលោកទាក់ទងនឹងជនពិការ និងនៅក្នុងវិធាននិយាមនានាស្តីពីការផ្តល់ឱកាសស្មើគ្នាដល់ជនពិការ ដើម្បីបញ្ចុះបញ្ចូលជំរុញបង្កើត និងវាយតម្លៃ គោលនយោបាយផែនការកម្មវិធី និងសកម្មភាពផ្សេងៗនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងលើឆាកអន្តរជាតិ ដើម្បីផ្តល់កាលានុវត្តភាពឲ្យបានស្មើគ្នាថែមទៀតដល់ជនពិការ ។

ឆ- ដោយគូសបញ្ជាក់បន្ថែមពីសារៈសំខាន់ នៃការបញ្ចូលបញ្ហាពិការភាពឲ្យទៅជាផ្នែកមួយពេញលេញនៃយុទ្ធសាស្ត្រពាក់ព័ន្ធនានា ក្នុងការអភិវឌ្ឍប្រកបដោយនិរន្តភាព ។

ជ- ដោយទទួលស្គាល់ផងដែរថា ការរើសអើងប្រឆាំងនឹងបុគ្គលណាមួយដោយសារតែពិការភាព គឺជាការរំលោភលើសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់មនុស្សដែល

មានពីកំណើត ។

ឈ- ដោយទទួលស្គាល់បន្ថែមទៀតពីពិការភាពផ្សេងគ្នារបស់ជនពិការ។

ញ- ដោយទទួលស្គាល់ពីតម្រូវការលើកស្ទួយ និងការពារសិទ្ធិមនុស្សរបស់ជនពិការគ្រប់រូប រួមទាំងអ្នកទាំងឡាយណាដែលត្រូវការគាំពារកម្រិតខ្ពស់ ។

ដ- ដោយមានការបារម្ភថា បើទោះជាមានឧបករណ៍ និងការជានារ៉ាប់រងផ្សេងៗយ៉ាងនេះក្តី ក៏ជនពិការនៅតែបន្តប្រឈមមុខនឹងឧបសគ្គ ក្នុងការចូលរួមរបស់គេដោយស្មើភាពគ្នាជាមួយសមាជិកឯទៀតក្នុងសង្គម និងការរំលោភសិទ្ធិមនុស្សរបស់ពួកគេនៅទូទាំងពិភពលោក ។

ឋ-ដោយទទួលស្គាល់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីលើកកម្ពស់ ស្ថានភាពរស់នៅរបស់ជនពិការ នៅគ្រប់ប្រទេស ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ ។

ឌ- ដោយទទួលស្គាល់ពីវិភាគទានដ៏មានតម្លៃ និងមានសក្តានុពលរបស់ជនពិការចំពោះសុខុមាលភាពទាំងស្រុង និងភាពផ្សេងៗគ្នានៃសហគមន៍របស់ខ្លួន និងការលើកស្ទួយជនពិការឲ្យទទួលបានពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត និងការចូលរួមយ៉ាងពេញលេញរបស់ពួកគេក្នុងសង្គម សម្រេចបានជាលទ្ធផល គឺការលើកកម្ពស់សតិអារម្មណ៍របស់ជនពិការថា ខ្លួនជាផ្នែកមួយនៃសង្គម និងភាពជឿនលឿនដ៏មានខ្លឹមសារក្នុងការអភិវឌ្ឍមនុស្ស សង្គមកិច្ច និងសេដ្ឋកិច្ច និងការលុបបំបាត់ភាពក្រីក្រ ។

ឍ- ដោយទទួលស្គាល់ពីសារៈសំខាន់នៃស្វ័យភាពជាឯកត្តបុគ្គល និងឯករាជ្យភាព

របស់ជនពិការ ម្នាក់ៗ រួមទាំងសេរីភាពក្នុងការមានជម្រើសរបស់ខ្លួនផ្ទាល់ ។

ណ- ដោយយល់ឃើញថា ជនពិការគួរតែមានឱកាសចូលរួមយ៉ាងសកម្មក្នុងដំណើរការធ្វើសេចក្តីសម្រេចអំពីគោលនយោបាយ និងកម្មវិធីនានា រួមទាំងកិច្ចការដែលពាក់ព័ន្ធនឹងបញ្ហារបស់ពួកគេផ្ទាល់ ។

ត- ដោយមានក្តីកង្វល់អំពីស្ថានភាពលំបាកដែលជនពិការបានជួបប្រទះនូវការរើសអើងជាច្រើន ឬការរើសអើងដែលមានទម្រង់ធ្ងន់ធ្ងរ ដោយឈរលើមូលដ្ឋាននៃការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា គំនិតនយោបាយ ឬទស្សនៈផ្សេងទៀត ជាតិពន្ធុប្រភពដើមជនជាតិ ឬសង្គម ទ្រព្យសម្បត្តិ ដើមកំណើត អាយុ ឬឋានៈផ្សេងៗទៀត ។

ថ- ដោយទទួលស្គាល់ថាស្ត្រី និងកុមារីពិការតែងតែជួបប្រទះនូវភយន្តរាយធំជាងគេទាំងនៅក្នុង និងក្រៅផ្ទះ ដូចជាអំពើហឹង្សា ការបង្ករបួសស្នាម ឬការបំពារបំពាន ការមិនអើពើ ឬការមិនស្និទ្ធស្នាល ការធ្វើទុក្ខបុកម្នេញ ឬការកេងប្រវ័ញ្ច ។

ទ- ដោយទទួលស្គាល់ថា កុមារពិការគួរតែបានទទួលយ៉ាងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយកុមារ ដទៃនិងដោយ រំលឹកឡើងវិញពីកាតព្វកិច្ចដែលត្រូវសម្រេចឲ្យបាននូវគោលដៅទាំងនេះ របស់រដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

ធ- ដោយគូសបញ្ជាក់ពីតម្រូវការ ដើម្បីដាក់បញ្ចូលទស្សនៈវិស័យផ្នែកយេនឌ័រ ទៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីលើកស្ទួយជនពិការឲ្យទទួលបានពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត។

ន- ដោយគូសបញ្ជាក់ពីភាពជាក់ស្តែង ដែលថាជនពិការភាគច្រើនរស់នៅក្នុងស្ថានភាព

គ្រីក្រហើយជាមួយនឹងស្ថានភាពបែបនេះ ដោយទទួលស្គាល់ពីតម្រូវការដ៏សំខាន់ក្នុងការលើកឡើងពីផលប៉ះពាល់ជាអវិជ្ជមាននៃភាពគ្រីក្រដល់ជនពិការ ។

ប- ដោយចងចាំថា លក្ខខណ្ឌនៃសន្តិភាព និងសន្តិសុខផ្អែកលើមូលដ្ឋាននៃការគោរពយ៉ាងពេញលេញនូវគោលបំណង និងគោលការណ៍ ដែលមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ និងការប្រតិបត្តិតាមលិខិតុបករណ៍សិទ្ធិមនុស្សដែលនៅមានជាធរមាន គឺជាប្រការសំខាន់បំផុត ដើម្បីការពារឲ្យបានពេញលេញដល់ជនពិការ ជាពិសេសនៅពេលមានជម្លោះប្រដាប់អាវុធ និងការចូលកាន់កាប់របស់បរទេស ។

ផ- ដោយទទួលស្គាល់អំពីសារៈសំខាន់នៃការទទួលបាននូវការសម្របសម្រួលដល់បរិយាកាសផ្នែកកាយសម្បទា សង្គមកិច្ច សេដ្ឋកិច្ចនិងវប្បធម៌ និងព័ត៌មានទំនាក់ទំនងអំពីសុខភាព ការអប់រំ ដើម្បីជួយឲ្យជនពិការអាចទទួលបានយ៉ាងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ។

ព-ដោយយល់យ៉ាងច្បាស់ថា បុគ្គលម្នាក់ៗដែលមានកាតព្វកិច្ចចំពោះអ្នកដទៃ និងចំពោះសហគមន៍របស់ខ្លួន ត្រូវមានការទទួលខុសត្រូវ ដើម្បីខិតខំប្រឹងប្រែងក្នុងការលើកស្ទួយ និងការប្រតិបត្តិតាមសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងក្រមអន្តរជាតិស្តីពីសិទ្ធិមនុស្ស ។

ភ- ដោយមានជំនឿថា គ្រួសារគឺជាសមាសធាតុដើម និងជាមូលដ្ឋាននៃសង្គម ហើយមានសិទ្ធិទទួលបាននូវកិច្ចការពារពីសង្គម និងរដ្ឋ ហើយជនពិការ និងសមាជិកក្រុមគ្រួសាររបស់ខ្លួនគួរទទួលបាននូវកិច្ចការពារ និងការជួយជ្រោមជ្រែងជាចាំបាច់ ដើម្បីឲ្យក្រុមគ្រួសារខ្លួនអាចចូលរួមចំណែកធ្វើឲ្យជនពិការទទួលបាននូវសិទ្ធិ ដោយស្មើភាព និងពេញលេញ។

ម- ដោយមានជំនឿថា អនុសញ្ញាអន្តរជាតិទាំងមូល និងគ្រប់ជ្រុងជ្រោយមួយ ដើម្បីការពារ និងលើកស្ទួយសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនពិការនឹងរួមវិភាគទានយ៉ាងថ្លៃថ្លា ក្នុងការកែតម្រូវគុណវិបត្តិសង្គមដ៏ជ្រាលជ្រៅចំពោះជនពិការ និងលើកស្ទួយជនពិការឲ្យមានឱកាសស្មើគ្នា ក្នុងការចូលរួមលើវិស័យពាក់ព័ន្ធដល់សិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទាំងក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ និងបណ្តាអារ្យប្រទេសបានព្រមព្រៀងដូចតទៅៈ

**មាត្រា១._**

**គោលបំណង**

គោលបំណងនៃអនុសញ្ញានេះ គឺដើម្បីជំរុញការពារ និងធានាឲ្យជនពិការទទួលបានដោយពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ និងដើម្បីលើកស្ទួយការគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើតមករបស់ជនពិការ។

ជនពិការសំដៅលើអ្នកទាំងឡាយដែលមានភាពអន់ខ្សោយរយៈពេលយូរ ផ្នែកកាយសម្បទា ផ្លូវចិត្ត សតិបញ្ញា ឬញាណដឹង ដែលនៅពេលជួបប្រទះជាមួយឧបសគ្គនានា អាចរារាំងពួកគេមិនឲ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គម ដោយស្មើភាពគ្នាជាមួយអ្នកដទៃបាន។

**មាត្រា២._**

**និយមន័យ**

គោលបំណងនៃអនុសញ្ញានេះគឺ ៖

- "ទំនាក់ទំនង" រាប់បញ្ចូលទាំងភាសា ការបង្ហាញជាអត្ថបទ អក្សរស្ទាប ទំនាក់ទំនងដោយការស្ទាប ការបោះពុម្ពជាអក្សរធំៗ ការដែលអាចទទួលបានប្រព័ន្ធពហុព័ត៌មាន ព្រមទាំងសំណេរ ខ្សែអាត់សំឡេង ភាសាសាមញ្ញៗ ឧបករណ៍បកស្រាយទិន្នន័យព័ត៌មានអំពីមនុស្ស និងវិធីសម្រាប់តម្លើង និងជំនួសផ្សេងៗ មធ្យោបាយ និងទម្រង់នានានៃការទំនាក់ទំនង រួមទាំងព័ត៌មានដែលអាចទទួលបាន និងបច្ចេកវិទ្យាទំនាក់ទំនង។

- "ភាសា" រួមបញ្ចូលទាំងភាសានិយាយ ភាសាសញ្ញា និងទម្រង់ផ្សេងៗទៀតនៃភាសាទាំងឡាយដែលគេមិននិយាយ។

- "ការរើសអើងដោយសារពិការភាព" មានន័យថា ការបែងចែក ការផាត់ចេញ ឬការដាក់កំហិតណាមួយដោយសារតែពិការភាព ដែលមានគោលបំណង ឬមានអានុភាពធ្វើឲ្យចុះទន់ខ្សោយ ឬលុបបំបាត់ការទទួលស្គាល់ ការទទួលបាន ឬប្រើប្រាស់នូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ពលរដ្ឋ ឬក្នុងវិស័យផ្សេងៗទៀត ។ ការរើសអើងនេះរាប់បញ្ចូលនូវរាល់ទម្រង់ នៃការរើសអើង រួមទាំងការបដិសេធនូវការសម្របសម្រួលសមស្រប។

- "ការសម្របសម្រួលសមស្រប"មានន័យថា ការកែឲ្យសមរម្យ និងចាំបាច់ និងការកែតម្រូវដែលមិនបង្ខំឲ្យការទទួលខុសត្រូវមានភាពវិសមាមាត្រ ឬ មិនត្រឹមត្រូវដែលមានភាពចាំបាច់តែក្នុងករណីពិសេស ដើម្បីធានាដល់ជនពិការឲ្យទទួលបាន និង

ប្រើប្រាស់បាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ។

- "ការរចនាជាសកល"មានន័យថា ការរចនាផលិតផល បរិស្ថាន កម្មវិធី និងសេវាកម្មផ្សេងៗ ដែលមនុស្សគ្រប់រូបអាចប្រើប្រាស់បានដោយមិនទាមទារការសម្រប តាម ឬការរចនាពិសេសផ្សេងទៀត ក្នុងវិសាលភាពធំបំផុតដែលអាចធ្វើបាន។ "ការរចនាជាសកល" មិនត្រូវផាត់ចោលឧបករណ៍ជំនួយទាំងឡាយពិសេសសម្រាប់ក្រុមជនពិការដែលត្រូវការឧបករណ៍ជំនួយទាំងនេះ ។

**មាត្រា៣._**

**គោលការណ៍ទូទៅ**

គោលការណ៍ទូទៅនៃអនុសញ្ញានេះមាន៖

ក. ការគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើត ស្វ័យភាពបុគ្គល រួមទាំងសេរីភាព ក្នុងការជ្រើសរើសដោយខ្លួនឯងផ្ទាល់ និងឯករាជ្យភាពរបស់បុគ្គល ។

ខ. ការមិនរើសអើង ។

គ. ការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាព និងការដាក់បញ្ចូលទៅក្នុងសង្គម ។

ឃ. ការគោរពភាពផ្សេងពីគេ និងការសុខចិត្តទទួលយកជនពិការ ជាចំណែកនៃភាពចម្រុះគ្នារបស់មនុស្ស និងមនុស្សជាតិ ។

ង. ឱកាសស្មើភាពគ្នា ។

ច. ការបង្កលក្ខណៈងាយស្រួល។

ឆ. សមភាពរវាងបុរស និងស្ត្រី។

ជ. ការគោរពសមត្ថភាពរីកចម្រើនរបស់កុមារពិការ និងការគោរពសិទ្ធិកុមារពិការ ដើម្បីរក្សានូវអត្តសញ្ញាណរបស់ពួកគេ ។

**មាត្រា៤._**

## **ភាតព្វកិច្ចទូទៅ**

១-រដ្ឋភាគីត្រូវធានា និងលើកស្ទួយសមិទ្ធិពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់សម្រាប់ជនពិការ ដោយគ្មានការរើសអើងចំពោះពិការភាពណាមួយឡើយ។ ដើម្បីសម្រេចបាននូវគោលដៅនេះ រដ្ឋភាគីត្រូវរ៉ាប់រងៈ

ក. អនុម័តរាល់វិធានការផ្លូវច្បាប់ រដ្ឋបាល និងវិធានការដទៃទៀតដែលសមស្រប ដើម្បីអនុវត្តនូវសិទ្ធិទាំងឡាយដែលត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញា នេះ ។

ខ. ចាត់រាល់វិធានការសមស្រប រួមទាំងវិធានការផ្នែកនីតិកម្ម ដើម្បីកែប្រែ ឬលុបចោលច្បាប់ បទបញ្ញា ទំនៀមទំលាប់ និងអនុវត្តន៍ជាក់ស្តែងដែលនៅធរមាន ហើយដែលបង្កើតការរើសអើងប្រឆាំងនឹងជនពិការ ។

គ. យកចិត្តទុកដាក់ដល់កិច្ចការពារ និងការលើកស្ទួយសិទ្ធិមនុស្សរបស់ជនពិការនៅរាល់គោលនយោបាយ និងកម្មវិធីទាំងអស់។

ឃ. ទប់ស្កាត់ពីការចូលរួមក្នុងអំពើ ឬអនុវត្តន៍ជាក់ស្តែងណាមួយដែលគ្មានសង្គតភាពជាមួយនឹងអនុសញ្ញានេះ ហើយធានាថា អាជ្ញាធរ និងស្ថាប័នសារធាណៈនានា

អនុវត្តស្របតាមអនុសញ្ញានេះ។

ង. ចាត់វាល់វិធានការសមស្រប ដើម្បីលុបបំបាត់ការរើសអើងពីពិការភាព ដោយបុគ្គលណាម្នាក់ អង្គការ ឬស្ថាប័នឯកជនណាមួយ ។

ច. ព្យាយាម ឬលើកស្ទួយការស្រាវជ្រាវ និងអភិវឌ្ឍនូវទំនិញ សេវាកម្ម សម្ភារ និងគ្រឿងបរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលរចនាឡើងជាសកលដូចបានចែងក្នុងមាត្រា២នៃអនុសញ្ញានេះ ដែលគួរតែតម្រូវឲ្យមានការសម្របតាមជាអប្បបរមាតាមតែអាចធ្វើបាន និងមានតម្លៃថោកដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ជនពិការក្នុងបំណងលើកស្ទួយការប្រើប្រាស់ និងលទ្ធភាពរបស់ខ្លួន ដើម្បីជំរុញការរចនាជាសកលក្នុងការរៀបចំនិយាម និងគោលការណ៍ណែនាំនានា។

ឆ. ព្យាយាម ឬលើកស្ទួយការស្រាវជ្រាវ ការអភិវឌ្ឍ ការប្រើប្រាស់ និងលទ្ធភាពបច្ចេកវិទ្យាថ្មីៗ រួមទាំងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង គ្រឿងជំនួយចល័ត ឧបករណ៍ និងបច្ចេកវិទ្យាជំនួយ ដែលសមស្របសម្រាប់ជនពិការ ដោយផ្តល់អាទិភាពចំពោះបច្ចេកវិទ្យាដែលមានតម្លៃសមរម្យ។

ជ. ផ្តល់ឲ្យជនពិការនូវលទ្ធភាពទទួលបាន ព័ត៌មានអំពីគ្រឿងជំនួយចល័ត ឧបករណ៍ទ្រទ្រង់រាងកាយ និងបច្ចេកវិទ្យាជំនួយ រួមទាំងបច្ចេកវិទ្យាថ្មីៗ ព្រមទាំងទម្រង់ផ្សេងៗទៀតនៃជំនួយសម្ភារ និងសេវាកម្មជួយគាំពារ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដទៃទៀត។

ឈ. ជំរុញការបណ្តុះបណ្តាលអ្នកមានវិជ្ជាជីវៈ និងបុគ្គលិកធ្វើការជាមួយជនពិការអំពីសិទ្ធិដែលត្រូវបានទទួលស្គាល់ក្នុងអនុសញ្ញានេះ ដើម្បីផ្តល់សេវាកម្ម និងជំនួយ

ឲ្យកាន់តែប្រសើរថែមទៀតដែលត្រូវបានធានាដោយសិទ្ធិទាំងនោះ។

២- ចំពោះសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការឲ្យបានជាអតិបរមា តាមធនធានដែលខ្លួនមាន និងតាមការចាំបាច់ នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងទស្សនៈសម្រេចឲ្យបានជាលំដាប់ និងពេញលេញនូវសិទ្ធិទាំងនេះ ដោយគ្មានធ្វើឲ្យខូចខាតដល់កាតព្វកិច្ចទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះដែលនឹងត្រូវតែអនុវត្តភ្លាមៗស្របតាមច្បាប់អន្តរជាតិ ។

៣- ក្នុងការកសាង និងអនុវត្តន៍ច្បាប់ និងគោលនយោបាយនានាដើម្បីអនុវត្តអនុសញ្ញានេះ និងក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចផ្សេងទៀត ស្តីពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងជនពិការ រដ្ឋភាគីត្រូវពិគ្រោះយោបល់យ៉ាងជិតស្និទ្ធនិងយ៉ាងសកម្មជាមួយជនពិការដែលពាក់ព័ន្ធ រួមទាំងកុមារពិការតាមរយៈអង្គការតំណាងរបស់ពួកគេ។

៤- គ្មានបទបញ្ញត្តិណាមួយនៅក្នុងអនុសញ្ញានេះ ប៉ះពាល់ដល់បទបញ្ញត្តិណាដែលនាំឲ្យសម្រេចបានថែមទៀតនូវសិទ្ធិទាំងឡាយរបស់ជនពិការ ដែលមានចែងនៅក្នុងច្បាប់របស់រដ្ឋភាគី ឬច្បាប់អន្តរជាតិដែលនៅជាធរមានចំពោះរដ្ឋនោះ។មិនត្រូវដាក់កំហិត ឬដកហូតសិទ្ធិណាមួយនៃសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តដែលត្រូវបានទទួលស្គាល់ ឬនៅមានជាធរមានក្នុងរដ្ឋភាគីណាមួយនៃអនុសញ្ញានេះទេ ដោយអនុលោមទៅតាមច្បាប់ អនុសញ្ញានានា បទបញ្ជា ឬទំនៀមទំលាប់ ដោយយកលេសថា អនុសញ្ញានេះមិនទទួលស្គាល់សិទ្ធិ ឬសេរីភាពបែបនេះ ឬក៏ថារដ្ឋភាគីនោះទទួលស្គាល់សិទ្ធិ និងសេរីភាពទាំងនេះក្នុងវិសាលភាពមួយតូចជាងនេះ។

៥- បទបញ្ញត្តិនៃអនុសញ្ញានេះត្រូវមានវិសាលភាព គ្របដណ្តប់ដល់ផ្នែកទាំងអស់នៃរដ្ឋសហព័ន្ធ ដោយគ្មានការកំណត់ ឬការលើកលែងណាមួយឡើយ ។

**មាត្រា៥._**

**សមភាព និងការមិនរើសអើង**

១- រដ្ឋភាគីទាំងឡាយទទួលស្គាល់ថា មនុស្សទាំងអស់ស្មើភាពគ្នាចំពោះមុខច្បាប់ និងស្ថិតនៅក្រោមច្បាប់ ហើយមានសិទ្ធិទទួលបានដោយគ្មានការរើសអើងណាមួយដល់កិច្ចការពារ និងផលប្រយោជន៍នៃច្បាប់ស្មើគ្នា។

២- រដ្ឋភាគីត្រូវហាមឃាត់រាល់ការរើសអើងដោយសារតែពិការភាព និងធានាដល់ជនពិការ នូវកិច្ចការពារតាមផ្លូវច្បាប់ស្មើគ្នា និងមានប្រសិទ្ធភាព ប្រឆាំងនឹងការរើសអើងតាមគ្រប់រូបភាព ។

៣-ដើម្បីលើកស្ទួយសមភាព និងលុបបំបាត់ការរើសអើង រដ្ឋភាគីត្រូវចាត់រាល់ដំណាក់កាលសមស្រប ដើម្បីធានានូវការផ្តល់ការសម្របសម្រួលសមស្រប។

៤- វិធានការជាក់លាក់ដែលចាំបាច់ដើម្បីបង្កើនល្បឿន ឬធ្វើឲ្យសម្រេចបាននូវសមភាពជាក់លាក់របស់ជនពិការ មិនត្រូវចាត់ទុកជាការរើសអើង ដូចមានចែងនៅក្នុងអនុសញ្ញានេះទេ។

**មាត្រា៦._**

**ស្ត្រីពិការ**

១- រដ្ឋភាគីទទួលស្គាល់ថា ស្ត្រីនិងកុមារីពិការងាយរងការរើសអើងច្រើនបែប

យ៉ាងណាស់ ហើយចំពោះបញ្ហានេះត្រូវចាត់វិធានការនានា ដើម្បីធានាឲ្យពួកគេទទួលបានភាពស្មើគ្នា និងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត។

២- រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ដើម្បីធានាឲ្យស្ត្រីទទួលបានការអភិវឌ្ឍ វឌ្ឍនភាព និងការផ្តល់សិទ្ធិអំណាចឲ្យបានពេញលេញ ដើម្បីធានាឲ្យពួកគេអនុវត្ត និងទទួលបាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តដូចមានចែងនៅក្នុងអនុសញ្ញានេះ។

**មាត្រា៧._**

## **កុមារពិការ**

១- រដ្ឋភាគីត្រូវចាត់រាល់វិធានការចាំបាច់នានា ដើម្បីធានាឲ្យកុមារពិការទទួលបានដោយពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយកុមារផ្សេងទៀត។

២- នៅគ្រប់សកម្មភាពដែលទាក់ទងនឹងកុមារពិការ ឧត្តមប្រយោជន៍របស់កុមារពិការត្រូវលើកយកមកពិចារណាមុនគេ។

៣- រដ្ឋភាគីត្រូវធានាថាកុមារពិការមានសិទ្ធិបញ្ចេញមតិរបស់ខ្លួន ដោយសេរីពីបញ្ហាគ្រប់បែបយ៉ាង ដែលប៉ះពាល់ដល់ពួកគេ។ ទស្សនៈរបស់ពួកគេត្រូវទទួលបានការពិចារណា ថ្លឹងថ្លែងឲ្យបានសមស្របទៅនឹងអាយុ និងភាពចាស់ទុំរបស់ពួកគេដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយកុមារផ្សេងទៀត ហើយពួកគេត្រូវទទួលបាននូវការជួយជ្រោមជ្រែងសមស្របទៅនឹងពិការភាព និងអាយុដើម្បីទទួលបាននូវសិទ្ធិនេះ

យ៉ាងពិតប្រាកដ ។

**មាត្រា៨._**

## **ការលើកកម្ពស់ការយល់ដឹង**

១- រដ្ឋភាគីត្រូវអនុម័តជាបន្ទាន់ នូវវិធានការសមស្រប និងមានប្រសិទ្ធភាព ដូចខាងក្រោមៈ

ក. លើកកម្ពស់ការយល់ដឹងអំពីជនពិការនៅក្នុងសង្គមជាតិទាំងមូល រួមទាំងនៅតាមគ្រួសារ និងលើកតម្កើងការគោរពសិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់ជនពិការ ។

ខ. ប្រយុទ្ធប្រឆាំងនឹងការរើសអើង ការប្រកាន់ពូជសាសន៍ និងការប្រព្រឹត្ត នាំឲ្យអន្តរាយផ្សេងៗដល់ជនពិការ រួមទាំងសកម្មភាពទាំងនោះទាក់ទងនឹងភេទ និងអាយុ គ្រប់ទិដ្ឋភាពនៃជីវិត ។

គ. ជំរុញការយល់ដឹងពីសមត្ថភាព និងការរួមវិភាគទានដល់ជនពិការ ។

២- វិធានការទាំងឡាយដើម្បីសម្រេចបាននូវគោលបំណងនេះរួមមាន ៖

ក. ផ្ដួចផ្ដើម និងថែរក្សាយុទ្ធនាការដើម្បីបង្កើនការយល់ដឹងជាសាធារណៈប្រកបដោយប្រសិទ្ធភាពដែលត្រូវបានរចនាឡើងសម្រាប់:

i) លើកទឹកចិត្តដល់ការចង់យល់ដឹងអំពីសិទ្ធិជនពិការ។

ii) ជំរុញការយល់ឃើញជាវិជ្ជមាន និងការយល់ដឹងពីសង្គមឲ្យកាន់តែទូលាយចំពោះជនពិការ ។

iii) ជំរុញការទទួលស្គាល់ជំនាញ គុណសម្បត្តិ និងលទ្ធភាពរបស់

ជនពិការ និងទទួលស្គាល់ការរួមវិភាគទានរបស់ពួកគេទាំងនៅទីកន្លែងធ្វើការ និងនៅទីផ្សារការងារ ។

ខ. លើកតម្កើងនៅគ្រប់កម្រិតនៃប្រព័ន្ធអប់រំ រួមទាំងកុមារតូចទាំងអស់នូវឥរិយាបទចេះគោរពសិទ្ធិរបស់ជនពិការ។

គ. ជំរុញគ្រប់ស្ថាប័នព័ត៌មានឲ្យផ្សព្វផ្សាយពីជនពិការក្នុងលក្ខណៈមួយស្របទៅតាមគោលបំណងនៃអនុសញ្ញានេះ។

ឃ.លើកស្ទួយកម្មវិធីបណ្តុះបណ្តាលការយល់ដឹងអំពីជនពិការ និងសិទ្ធិរបស់ជនពិការ។

**មាត្រា៩._**

**ភាពងាយស្រួល**

១- ដើម្បីជួយជនពិការឲ្យរស់នៅដោយឯករាជ្យ និងចូលរួមយ៉ាងពេញលេញក្នុងគ្រប់ទិដ្ឋភាពនៃជីវិតរដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីធានាដល់ជនពិការដោយឈរលើមូលដ្ឋានស្មើភាពគ្នា ជាមួយអ្នកផ្សេងទៀតទទួលបាននូវបរិស្ថានរូបវន្តមធ្យោបាយធ្វើដំណើរព័ត៌មាននិងទំនាក់ទំនង រួមទាំងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសេវាកម្មផ្សេងទៀតដែលបើកឬផ្តល់ឲ្យប្រើប្រាស់ជាសាធារណៈ ទាំងនៅទីក្រុងទាំងនៅតាមទីជនបទ។ វិធានការទាំងនេះរួមបញ្ចូលនូវអត្តសញ្ញាណ និងការលុបបំបាត់ឧបសគ្គ និងរបាំងទាំងឡាយដល់ការទទួលបាននូវសិទ្ធិទាំងនេះ និងត្រូវអនុវត្តចំពោះ ៖

ក. អគារ ផ្លូវថ្នល់ មធ្យោបាយធ្វើដំណើរ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងផ្ទះ និងក្រៅផ្ទះផ្សេងៗទៀតរួមទាំងសាលារៀន លំនៅដ្ឋាន គ្រឹះស្ថានសុខាភិបាល និងកន្លែងការងារ ។

ខ. ព័ត៌មាន ទំនាក់ទំនង និងសេវាកម្មដទៃទៀត រួមទាំងសេវាកម្មអេឡិចត្រូនិច និងសេវាកម្មសង្គ្រោះបន្ទាន់។

២- រដ្ឋភាគីត្រូវចាត់វិធានការសមស្របផងដែរដើម្បី ៖

ក. កសាង ប្រកាសឲ្យប្រើប្រាស់ និងតាមដានអនុវត្តន៍គោលការណ៍ណែនាំ និងបទដ្ឋានអប្បបរមា សម្រាប់ការទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសេវាកម្មដែលបើក និងផ្តល់ជាសាធារណៈ។

ខ. ធានាថា អង្គភាពឯកជនដែលផ្តល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបើក ឬ ផ្តល់ជាសាធារណៈត្រូវពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយពីការបង្កលក្ខណៈងាយស្រួលដល់ជនពិការ ។

គ.ផ្តល់ការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធ ពីបញ្ហារបស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលប្រឈមជាមួយជនពិការ ។

ឃ.ដាក់ស្លាកសញ្ញាជាអក្សរស្ទាប និងជាទម្រង់ងាយអាន ងាយយល់ នៅតាមអគារ និងទីកន្លែងសាធារណៈដទៃទៀត។

ង. ផ្តល់ទម្រង់ផ្សេងៗនៃជំនួយដល់ការរស់នៅនិងអន្តរការី រួមបញ្ចូលអ្នកនាំផ្លូវ អ្នកជំនាញអាន និងអ្នកមានអាជីពបកប្រែភាសាសញ្ញា ដើម្បីបង្កភាពងាយស្រួលដល់ការប្រើប្រាស់អគារ និងទីកន្លែងសាធារណៈផ្សេងទៀតបាន។

ច. ជំរុញការជួយគ្រប់បែប និងការគាំពារសមស្របដទៃទៀតដល់ជនពិការដើម្បីធានា ថាពួកគេទទួលបាននូវព័ត៌មាន ។

ឆ. ជំរុញឲ្យជនពិការទទួលបាននូវប្រព័ន្ធ និងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងថ្មីៗ រួមទាំងអ៊ិនធឺណែតផងដែរ។

ជ. ជំរុញឲ្យមានការរចនាការអភិវឌ្ឍផលិតកម្ម និងការចែកចាយនូវប្រព័ន្ធ និងបច្ចេកវិទ្យាព័ត៌មានដែលអាចទទួលបាននៅដំណាក់កាលដំបូង ដូច្នេះប្រព័ន្ធនឹងបច្ចេកវិទ្យាទាំងនេះនិងមានតម្លៃថោកល្មមអាចទទួលយកបាន។

**មាត្រា១០._**

## សិទ្ធិរស់រានមានជីវិត

រដ្ឋភាគីអះអាងជាថ្មីថា មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិតចាប់តាំងពីកំណើតមក និងត្រូវចាត់វាល់វិធានការចាំបាច់ ដើម្បីធានាឲ្យជនពិការទទួលបានដោយប្រសិទ្ធភាព និងស្មើភាពជាមួយអ្នកដទៃទៀតដែរ។

**មាត្រា១១._**

## ស្ថានភាពនៃហានិភ័យនិងស្ថានភាពបន្ទាន់ផ្នែកមនុស្សធម៌

អនុលោមតាមកាតព្វកិច្ចរបស់ខ្លួនចំពោះច្បាប់អន្តរជាតិ រួមទាំងច្បាប់មនុស្សធម៌ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ រដ្ឋភាគីត្រូវចាត់វាល់វិធានការចាំបាច់ ដើម្បីធានាដល់កិច្ចការពារ និងសុវត្ថិភាពរបស់ជនពិការ ក្នុងស្ថានភាពនៃហានិភ័យ រួមទាំងជម្លោះប្រដាប់អាវុធ ស្ថានភាពបន្ទាន់ផ្នែកមនុស្សធម៌ និងការកើតឡើងនៃគ្រោះមហន្តរាយពីធម្មជាតិ ។

## មាត្រា១២._

## ការទទួលស្គាល់ភាពស្មើគ្នាចំពោះមុខច្បាប់

១- រដ្ឋភាគីអះអាងជាថ្មីថាជនពិការមានសិទ្ធិត្រូវបានទទួលស្គាល់នៅគ្រប់ទីកន្លែងទាំងអស់ ដូចជាមនុស្ស ទូទៅចំពោះមុខច្បាប់ ។

២- រដ្ឋភាគីត្រូវទទួលស្គាល់ថា ជនពិការមានសមត្ថភាពតាមផ្លូវច្បាប់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត ក្នុងគ្រប់ទិដ្ឋភាពនៃជីវិត ។

៣- រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានា ដើម្បីផ្តល់លទ្ធភាពឲ្យជនពិការទទួលបានការជួយឧបត្ថម្ភ ដែលពួកគេត្រូវការក្នុងការអនុវត្តសមត្ថភាពតាមផ្លូវច្បាប់របស់ខ្លួន ។

៤- រដ្ឋភាគីត្រូវធានាថា រាល់វិធានការដែលពាក់ព័ន្ធនឹងអនុវត្តន៍សមត្ថភាពតាមផ្លូវច្បាប់ផ្តល់នូវកិច្ចការពារយ៉ាងសមរម្យ និងមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការបំពាន ដោយអនុលោមតាមច្បាប់សិទ្ធិមនុស្ស អន្តរជាតិ។ កិច្ចការពារបែបនេះត្រូវធានាថា វិធានការទាំងឡាយដែលទាក់ទងនឹងការអនុវត្តសមត្ថភាព តាមផ្លូវច្បាប់ គោរពសិទ្ធិ ឆន្ទៈ និងចំណង់ចំណូលចិត្តរបស់ជនពិការ ត្រូវបានរួចផុតពីទំនាស់ផលប្រយោជន៍ និងឥទ្ធិពលមិនត្រឹមត្រូវ និងសមាមាត្រ ដោយបន្ថែមបន្ថយទៅតាមកាលៈទេសៈរបស់បុគ្គលម្នាក់ៗ អនុវត្តន៍ក្នុងរយៈពេលខ្លីបំផុត តាមដែលអាចធ្វើទៅបាន និងជាប្រធានបទដែលត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ ដោយអាជ្ញាធរមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀងមួយ ឬស្ថាប័នតុលាការ។ កិច្ចការពារទាំងនេះត្រូវតែសមាមាត្រទៅនឹង

កម្រិតដែលវិធានការបែបនេះប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ដល់បុគ្គលនោះ ។

៥- អនុលោមតាមបទបញ្ញត្តិនៃមាត្រានេះ រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្រប និងមានប្រសិទ្ធភាព ដើម្បីធានាឲ្យជនពិការមានសិទ្ធិស្មើគ្នា ក្នុងការធ្វើជាម្ចាស់លើទ្រព្យសម្បត្តិ ឬទទួលមរតក ក្នុងការត្រួតពិនិត្យកិច្ចការហិរញ្ញវត្ថុផ្ទាល់ខ្លួនផ្សេងៗ និងមានសិទ្ធិស្មើគ្នាចំពោះការខ្ចីឥណទានធនាគារ ការបញ្ចាំ និងទម្រង់ផ្សេងៗទៀតនៃឥណទានហិរញ្ញវត្ថុ ហើយត្រូវធានាថា ជនពិការមិនត្រូវបានគេដកហូតយកទ្រព្យសម្បត្តិរបស់ពួកគេ តាមអំពើចិត្តនោះទេ ។

**មាត្រា១៣._**

**ការទទួលបានយុត្តិធម៌**

១- រដ្ឋភាគីត្រូវធានាពីសិទ្ធិទទួលបានសេវាយុត្តិធម៌ ដែលមានប្រសិទ្ធភាពសម្រាប់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀតតាមរយៈបទបញ្ញត្តិនៃដំណោះស្រាយសមស្របតាមអាយុ និងតាមនីតិវិធី ដើម្បីជួយសម្រួលតួនាទីដ៏មានប្រសិទ្ធភាពរបស់ពួកគេ ទោះក្នុងនាមជាអ្នកចូលរួមដោយផ្ទាល់ឬដោយប្រយោលក្តីរួមទាំងធ្វើជាសាក្សីនៅរាល់ចំណាត់ការរឿងក្តី នៅដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលដំបូងផ្សេងៗទៀត។

២- ដើម្បីជួយធានាពីសិទ្ធិទទួលបានសេវាយុត្តិធម៌ ដែលមានប្រសិទ្ធភាពសម្រាប់ជនពិការ រដ្ឋភាគីត្រូវជំរុញការបណ្តុះបណ្តាលឲ្យបានសមស្របដល់អ្នកទាំងឡាយដែលកំពុងបម្រើការងារនៅក្នុងវិស័យយុត្តិធម៌ រួមទាំងនគរបាល និងបុគ្គលិកពន្ធនាគារ

ផងដែរ ។

**មាត្រា១៤._**

**សិទ្ធិសេរីភាព និង សន្តិសុខបុគ្គល**

១- ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត រដ្ឋភាគីត្រូវធានាថាជនពិការ ៖

ក. ទទួលបានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

ខ. មិនត្រូវបានដកហូតសេរីភាពរបស់ពួកគេដោយខុសច្បាប់ ឬតាមទំនើងចិត្តឡើយ ហើយធានាថាការដកហូតសេរីភាពណាមួយត្រូវតែអនុលោមទៅតាមច្បាប់ និងធានាថាគ្មានការដកហូតសេរីភាព ដោយសំអាងលើពិការភាពទោះក្នុងករណីណាក៏ដោយ ។

២- រដ្ឋភាគីត្រូវធានាថា ប្រសិនបើជនពិការត្រូវបានដកហូតសេរីភាពទោះតាមនីតិវិធីណាក៏ដោយ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ជនពិការមានសិទ្ធិទទួលបាននូវការធានារ៉ាប់រង អនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយការប្រព្រឹត្តចំពោះជនពិការត្រូវស្របតាមគោលបំណង និងគោលការណ៍នៃអនុសញ្ញានេះ រួមទាំងការផ្តល់ការសម្របសម្រួលសមស្រប ។

**មាត្រា១៥._**

**សេរីភាពចាកផុតពីការធ្វើទារុណកម្ម ឬការធ្វើអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬការដាក់ទារុណកម្ម**

១-គ្មាននរណាម្នាក់ត្រូវទទួលរងការធ្វើបាប ឬ អំពើឃោរឃៅអមនុស្សធម៌ ឬ បន្ទាបបន្ថោកឬការដាក់ទារុណកម្ម។ ជាពិសេស គ្មាននរណាម្នាក់ត្រូវទទួលរងនូវការ ធ្វើពិសោធន៍វេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដោយគ្មានការស្ម័គ្រចិត្តយល់ព្រមពីសាមីខ្លួនឡើយ ។

២- រដ្ឋភាគីត្រូវចាត់រាល់វិធានការតាមផ្លូវច្បាប់ ផ្លូវរដ្ឋបាល ផ្លូវតុលាការ ឬ វិធានការដទៃទៀតឲ្យមានប្រសិទ្ធភាព ដើម្បីការពារជនពិការឲ្យរួចចាកផុតពីការធ្វើបាប ឬអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬការដាក់ទារុណកម្ម ដោយឈរលើមូលដ្ឋានមួយស្មើភាពគ្នាជាមួយអ្នកដទៃ។

**មាត្រា១៦._**

## សេរីភាពចាកផុតពីការកេងប្រវ័ញ្ច អំពើហិង្សា និងការ រំលោភបំពាន

១- រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្របតាមផ្លូវច្បាប់ រដ្ឋបាល សង្គម អប់រំ និងវិធានការដទៃទៀត ដើម្បីការពារជនពិការទាំងក្នុងផ្ទះ ទាំងក្រៅផ្ទះ ពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន រួមទាំងទិដ្ឋភាពនានាដោយឈរលើមូលដ្ឋានយេនឌ័ររបស់ខ្លួនផង ។

២- រដ្ឋភាគីក៏ត្រូវចាត់រាល់វិធានការសមស្រប ដើម្បីទប់ស្កាត់គ្រប់ទម្រង់នៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន ដោយធានាឲ្យមានទម្រង់សមស្របនៃការជួយឧបត្ថម្ភ និងការគាំទ្រដែលឆ្លើយតបបានទៅនឹងតម្រូវការតាមអាយុ និងយេនឌ័រ ដល់ជនពិការ ក្រុមគ្រួសារ និងអ្នកថែទាំរបស់គេ រួមទាំងតាមរយៈការផ្តល់ព័ត៌មាន និង

ការអប់រំ អំពីវិធីចៀសវាង ទទួលស្គាល់ និងរាយការណ៍ ជាបន្ទាន់អំពីករណីនានានៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន ។ រដ្ឋភាគីត្រូវធានាថា សេវាកម្មការពារទាំងនោះត្រូវមានលក្ខណៈឆ្លើយតបទៅតាមតម្រូវការនៃអាយុ យេនឌ័រ និងពិការភាព ។

៣-ដើម្បីទប់ស្កាត់ការកើតឡើងនៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន តាមគ្រប់រូបភាព រដ្ឋភាគីត្រូវធានាថាកម្មវិធី និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់បែបយ៉ាង ដែលរចនាឡើងដើម្បីបម្រើជនពិការ ត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់បំផុតដោយអាជ្ញាធរឯករាជ្យ ។

៤- រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ដើម្បីជំរុញការធ្វើឲ្យប្រសើរឡើងវិញ ខាងផ្លូវចិត្តសតិបញ្ញា និងកាយសម្បទា ការស្តារលទ្ធភាពពលកម្ម និងការធ្វើសមាហរណកម្មចូលក្នុងសង្គមជាតិវិញនៃជនពិការ ដែលជាជនរងគ្រោះពីទម្រង់ណាមួយនៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន រួមទាំងតាមរយៈការផ្តល់សេវាកម្មការពារ។ ការធ្វើឲ្យប្រសើរឡើងវិញ និងការធ្វើសមាហរណកម្មឡើងវិញបែបនេះ ត្រូវកើតឡើងក្នុងបរិយាកាសមួយ ដែលទ្រទ្រង់ដល់សុខភាព សុខុមាលភាព ការគោរពបុគ្គល សេចក្តីថ្លៃថ្នូរ និងស្វ័យភាពរបស់បុគ្គល និងត្រូវគិតគូរដល់តម្រូវការជាក់ស្តែងតាមអាយុ និងយេនឌ័រ ។

៥- រដ្ឋភាគីត្រូវបង្កើតច្បាប់ និងគោលនយោបាយដែលមានប្រសិទ្ធភាព រួមទាំងច្បាប់ និងគោលនយោបាយរួមទាំងការយកចិត្តទុកដាក់ដល់ស្ត្រី និងកុមារ ដើម្បីធានាថា ករណីនៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពានលើជនពិការត្រូវបានកំណត់ជាមុខសញ្ញា ស្ថិតក្រោមការស៊ើបអង្កេត និងចោទប្រកាន់ឲ្យបានត្រឹមត្រូវ ។

**មាត្រា១៧._**

**កិច្ចការពារសុចរិតភាពនៃបុគ្គល**

ជនពិការគ្រប់រូបមានសិទ្ធិគោរពចំពោះសុចរិតភាពផ្លូវកាយ និងផ្លូវចិត្តរបស់ខ្លួនដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ ។

**មាត្រា១៨._**

**សិទ្ធិសេរីភាពនៃចល័តទី និងសញ្ជាតិ**

១- រដ្ឋភាគីត្រូវទទួលស្គាល់សិទ្ធិរបស់ជនពិការ ចំពោះសិទ្ធិសេរីភាពក្នុងការចល័តទី សេរីភាពក្នុងការជ្រើសរើសទីលំនៅ និងសញ្ជាតិរបស់ខ្លួន ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ រួមទាំងការធានាឲ្យជនពិការ ៖

ក. មានសិទ្ធិទទួលបាន និងប្តូរសញ្ជាតិ ហើយមិនត្រូវដកហូតសញ្ជាតិរបស់ពួកគេដោយមិនសមហេតុផល ឬដោយសារតែពិការភាពនោះទេ ។

ខ. ដោយសារតែពិការភាពលទ្ធភាពរបស់ពួកគេ មិនត្រូវដកហូតក្នុងការទទួលបានការកាន់កាប់ និងការប្រើប្រាស់ឯកសារសញ្ជាតិ ឬឯកសារដទៃទៀតនៃអត្តសញ្ញាណ ឬក្នុងការប្រើប្រាស់នីតិវិធីពាក់ព័ន្ធនានា ដូចជានីតិវិធីអន្តោប្រវេសន៍ជាដើម ដែលពួកគេអាចត្រូវការ ដើម្បីសម្រួលដល់ការអនុវត្តសិទ្ធិសេរីភាពក្នុងការចល័តទី។

គ. មានសេរីភាពចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសកំណើតរបស់ខ្លួនផងដែរ។

ឃ. មិនត្រូវដកហូតសិទ្ធិចូលក្នុងប្រទេសរបស់ខ្លួនតាមទំនើងចិត្ត ឬ

ដោយសារតែពិការភាពនោះឡើយ ។

២- កុមារពិការត្រូវបានចុះបញ្ជីភ្លាមបន្ទាប់ពីប្រសូត និងត្រូវមានសិទ្ធិពីកំណើតក្នុងការទទួលបានឈ្មោះមួយ សិទ្ធិទទួលបានសញ្ជាតិមួយ និងតាមលទ្ធភាពដែលអាចធ្វើបាន មានសិទ្ធិស្គាល់ឪពុកម្តាយ និងទទួលបានការថែទាំពីឪពុកម្តាយ។

**មាត្រា១៩._**

## ការរស់នៅដោយឯករាជ្យ និងរួមបញ្ចូលក្នុងសហគមន៍

រដ្ឋភាគីនៃអនុសញ្ញានេះទទួលស្គាល់សិទ្ធិស្មើភាពគ្នារបស់ជនពិការក្នុងការរស់នៅក្នុងសហគមន៍ ដោយស្មើភាពគ្នាជាមួយអ្នកផ្សេងទៀតក្នុងការជ្រើសរើស ហើយត្រូវចាត់វិធានការសមស្រប និងមានប្រសិទ្ធភាព ដើម្បីជួយឲ្យជនពិការទទួលបានយ៉ាងពេញលេញនូវសិទ្ធិនេះ ការរួមបញ្ចូល និងការចូលរួមយ៉ាងពេញលេញរបស់ជនពិការក្នុងសហគមន៍ដោយធានាថា៖

ក. ជនពិការមានឱកាសជ្រើសរើសកន្លែងតាំងទីលំនៅ និងទីកន្លែងរបស់ខ្លួន និងអ្នកដែលគេត្រូវរស់នៅជាមួយ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត និងមិនត្រូវបានគេបង្ខំឲ្យរស់នៅតាមការរៀបចំជាពិសេសណាមួយឡើយ។

ខ. ជនពិការទទួលបានសេវាគាំទ្រការរស់នៅ កន្លែងស្នាក់អាស្រ័យ និងសេវាគាំទ្រសហគមន៍ផ្សេងៗ រួមទាំងជំនួយបុគ្គលដែលចាំបាច់ដើម្បីគាំទ្រការរស់នៅ និងការបញ្ចូលខ្លួនទៅក្នុងសហគមន៍ និងបង្ការពីភាពឯកោ ឬការឃ្លាតឆ្ងាយពីសហគមន៍ ។

គ. សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសហគមន៍សម្រាប់ប្រជាពលរដ្ឋ

ទូទៅក៏ដូចជា សម្រាប់ជនពិការដែរ ដោយឈរលើមូលដ្ឋានស្មើភាព និងឆ្លើយតបបាន ទៅនឹងតម្រូវការរបស់ពួកគេ។

**មាត្រា២០._**

## ការចល័តទីផ្ទាល់ខ្លួន

រដ្ឋភាគីត្រូវចាត់វិធានការមានប្រសិទ្ធភាពនានា ដើម្បីធានាការចល័តផ្ទាល់ខ្លួន ប្រកបដោយលទ្ធភាពឯករាជ្យល្អបំផុតសម្រាប់ជនពិការរួមមាន៖

ក. ការជួយសម្រួលការចល័តទីផ្ទាល់ខ្លួនរបស់ជនពិការ ក្នុងលក្ខណៈនិងតាមពេលវេលានៃការជ្រើសរើសរបស់គេ និងមានតម្លៃសមរម្យ។

ខ. ការជួយសម្រួលឲ្យជនពិការមានលទ្ធភាពទទួលបានឧបករណ៍ជំនួយដល់ការចល័តទីឧបករណ៍ទ្រទ្រង់រាងកាយ បច្ចេកវិទ្យានៃគ្រឿងជំនួយដែលមានគុណភាព និងទម្រង់ផ្សេងៗនៃជំនួយដល់ការរស់នៅនិងអន្តរការី រួមទាំងការធ្វើឲ្យសម្ភារទាំងនេះស្ថិតក្នុងតម្លៃសមរម្យ ។

គ. ការផ្តល់ការបណ្តុះបណ្តាលទាក់ទងនឹងការចល័តទីដល់ជនពិការ និងដល់បុគ្គលិកឯកទេសដែលធ្វើការជាមួយជនពិការ។

ឃ. ការលើកទឹកចិត្តអង្គភាពនានាដែលផលិតឧបករណ៍ជំនួយដល់ការចល័តទី ឧបករណ៍ទ្រទ្រង់រាងកាយ បច្ចេកវិទ្យានៃគ្រឿងជំនួយឲ្យគិតពិចារណាដល់គ្រប់ទិដ្ឋភាពនៃការចល័តទីរបស់ជនពិការ ។

**មាត្រា២១._**

## សេរីភាពនៃការបញ្ចេញមតិយោបល់ និងសិទ្ធិទទួលបាន ព័ត៌មាន

រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ដើម្បីធានាថាជនពិការអាចអនុវត្តសិទ្ធិសេរីភាពបានក្នុងការបញ្ចេញមតិយោបល់ រួមទាំងសេរីភាពក្នុងការស្វែងរក ទទួល និងផ្តល់ព័ត៌មាន និងទស្សនៈដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ និងតាមរយៈគ្រប់ទម្រង់នៃទំនាក់ទំនង ស្របតាមការជ្រើសរើសរបស់គេ ដូចដែលមានចែងនៅក្នុងមាត្រា២ នៃអនុសញ្ញានេះ រួមទាំង ៖

ក. ការផ្តល់ព័ត៌មានជាសាធារណៈឲ្យដល់ជនពិការ តាមទម្រង់ និងបច្ចេកវិទ្យាដែលគេអាចទទួលបានសមស្រប ទៅនឹងប្រភេទផ្សេងៗនៃពិការភាព ឲ្យបានទាន់ពេលវេលា និងគ្មានការបង់ប្រាក់បន្ថែម ។

ខ. ការទទួល និងជួយសម្រួលដល់ការប្រើប្រាស់ភាសាសញ្ញា អក្សរស្ទាប និងទំនាក់ទំនងផ្សេងៗទៀត ព្រមទាំងគ្រប់មធ្យោបាយ របៀប និងទម្រង់នៃទំនាក់ទំនងផ្សេងទៀត ដែលអាចទទួលយកបានតាមការជ្រើសរើសរបស់ជនពិការ ក្នុងការទាក់ទងជាផ្លូវការ ។

គ. ការជំរុញឲ្យនីតិបុគ្គលឯកជននានា ដែលផ្តល់សេវាកម្មផ្សេងៗជាសាធារណៈ រួមទាំងតាមរយៈអ៊ិនធឺណែត ផ្តល់ព័ត៌មាន និងសេវាកម្មផ្សេងៗតាមទម្រង់ដែលជនពិការអាចទទួល និងប្រើប្រាស់បាន ។

ឃ. ការលើកទឹកចិត្តដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន រួមទាំងអ្នកផ្តល់ព័ត៌មាន

តាមរយៈប្រព័ន្ធអ៊ិនធឺណែត ដើម្បីធ្វើឲ្យជនពិការអាចទទួលយកសេវាកម្មទាំងនោះបាន។

ង. ការទទួលស្គាល់ និងការជំរុញការប្រើប្រាស់ភាសាសញ្ញា ។

**មាត្រា២២._**

## ការគោរពសិទ្ធិបុគ្គល

១- ដោយមិនគិតពីកន្លែងស្នាក់អាស្រ័យ ឬ ការរៀបចំរបៀបរស់នៅរបស់ពួកគេ គ្មានជនពិការណាម្នាក់ត្រូវទទួលរងការជ្រៀតជ្រែកសិទ្ធិបុគ្គល គ្រួសារ ផ្ទះសំបែង ឬលិខិតឆ្លើយឆ្លង ឬប្រភេទផ្សេងៗទៀតនៃទំនាក់ទំនងរបស់គេតាមទំនើងចិត្ត ឬ ដោយខុសច្បាប់ ឬទទួលរងការបំពារបំពានមិនស្របច្បាប់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ពួកគេឡើយ។ ជនពិការមានសិទ្ធិទទួលបានកិច្ចការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬការបំពារបំពានទាំងនេះ។

២- រដ្ឋភាគីត្រូវការពារសិទ្ធិផ្ទាល់ខ្លួនរបស់បុគ្គលក្នុងការទទួលព័ត៌មានពីសុខភាព និងស្តារលទ្ធភាពពលកម្មរបស់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។

**មាត្រា២៣._**

## ការគោរពលំនៅដ្ឋាន និងគ្រួសារ

១- រដ្ឋភាគីត្រូវចាត់វិធានការនានាដែលសមស្រប និងមានប្រសិទ្ធភាពដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងជនពិការតាមគ្រប់ទម្រង់ដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ គ្រួសារមាតាបិតាភាព និងសាច់ញាតិ ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ ធ្វើដូច្នេះដើម្បីធានាថា៖

ក. សិទ្ធិជនពិការគ្រប់រូបដែលដល់វ័យរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារមួយ ដោយឈរលើមូលដ្ឋានព្រមព្រៀងពេញលេញ និងដោយសេរីពីអនាគតសហព័ទ្ធត្រូវបានស្គាល់ដោយច្បាប់។

ខ. សិទ្ធិជនពិការក្នុងការសម្រេចចិត្តដោយសេរី និងដោយទទួលខុសត្រូវលើការកំណត់ចំនួនកូន និងចន្លោះពេលមានកូន និងការទទួលព័ត៌មានសមស្របទៅតាមវ័យអំពីការអប់រំនៃសុខភាពបន្តពូជនិងការពន្យារកំណើត ត្រូវបានទទួលស្គាល់ដោយច្បាប់ហើយមធ្យោបាយចាំបាច់នានាដែលជួយឲ្យពួកគេអាចអនុវត្តសិទ្ធិទាំងនេះបានត្រូវបានផ្តល់ជូន។

គ. ជនពិការ រួមទាំងកុមារមានសិទ្ធិរក្សាគភ៌របស់ខ្លួន ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។

២- រដ្ឋភាគីត្រូវធានាពីសិទ្ធិ និងការទទួលខុសត្រូវរបស់ជនពិការទាក់ទងនឹងអាណាព្យាបាលភាព ការគ្រប់គ្រងកុមារ ការបង្កើតមូលនិធិមនុស្សធម៌ ការចិញ្ចឹមក្មេង ឬ ស្ថាប័ននានាដែលស្រដៀងគ្នា ដែលទស្សនាទានទាំងនោះមាននៅក្នុងច្បាប់ជាតិ នៅគ្រប់ករណីឧត្តមប្រយោជន៍របស់កុមារត្រូវតែមានឧត្តមភាព។ រដ្ឋភាគីត្រូវផ្តល់ជំនួយសមស្របដល់ជនពិការ ក្នុងការបំពេញការទទួលខុសត្រូវចិញ្ចឹមកូនរបស់ពួកគេ។

៣- រដ្ឋភាគីត្រូវធានាថា កុមារពិការមានសិទ្ធិស្មើគ្នាពាក់ព័ន្ធនឹងជីវិតគ្រួសារ ។ ដើម្បីធ្វើឲ្យសម្រេចបានសិទ្ធិទាំងនេះ និងដើម្បីបង្ការការបិទបាំង ការបំបរបង់ ការមិនយកចិត្តទុកដាក់ និងការដាក់កុមារពិការឲ្យនៅឯកោ រដ្ឋភាគីត្រូវផ្តល់ព័ត៌មាន សេវាកម្ម

និងការជួយឧបត្ថម្ភដល់កុមារពិការ និងក្រុមគ្រួសាររបស់ពួកគេ ឲ្យបានចាប់ពីដំណាក់កាលដំបូង និងគ្រប់ជ្រុងជ្រោយ។

៤- រដ្ឋភាគីត្រូវធានាថា កុមារមិនត្រូវបានបំបែកឲ្យរស់នៅទីទៃពីឪពុកម្តាយដោយផ្ទុយពីបំណងរបស់គេឡើយ លើកលែងតែដោយអាជ្ញាធរមានសមត្ថកិច្ច ដែលសម្រេចតាមការវិនិច្ឆ័យរបស់តុលាការ ដោយអនុលោមតាមច្បាប់ និងនីតិវិធីដែលនៅមានជាធរមាន ថាការបំបែកបែបនេះមានលក្ខណៈចាំបាច់សម្រាប់ឧត្តមប្រយោជន៍របស់កុមារ។ គ្មានករណីណាដែលកុមារត្រូវបានបំបែកពីឪពុកម្តាយ ដោយសារតែពិការភាពរបស់កុមារ ឬដោយសារតែពិការភាពរបស់ឪពុក ឬម្តាយ ឬដោយសារតែឪពុកម្តាយពិការទាំងពីរនាក់នោះឡើយ។

៥- ក្នុងករណីដែលគ្រួសាររបស់កុមារពិការផ្ទាល់ មិនអាចបីបាច់ថែរក្សាកុមារពិការបាន រដ្ឋភាគីត្រូវខិតខំគ្រប់បែបយ៉ាង ដើម្បីផ្តល់ការថែទាំជំនួសក្នុងរង្វង់គ្រួសារមួយដែលធំជាងមុន ហើយបើមិនបានដូច្នេះទេ គួរតែនៅក្នុងរង្វង់សហគមន៍មួយដែលមានការរៀបចំជាលក្ខណៈគ្រួសារ។

**មាត្រា២៤._**

**ការអប់រំ**

១- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការចំពោះការអប់រំ។ ក្នុងទស្សនៈដើម្បីធ្វើឲ្យសិទ្ធិនេះបានសម្រេចដោយគ្មានការរើសអើង និងដោយឈរលើមូលដ្ឋាននៃការផ្តល់ឱកាសស្មើភាពគ្នា រដ្ឋភាគីត្រូវធានាឲ្យ មានប្រព័ន្ធអប់រំបញ្ចូលគ្នាមួយ នៅគ្រប់

កម្រិតសិក្សា និងការសិក្សាពេញមួយជីវិតដែលមានការតម្រង់ទិសទៅរកៈ

ក. ការអភិវឌ្ឍទាំងស្រុងនៃសក្តានុពលមនុស្ស សេចក្តីថ្លៃថ្នូរ តម្លៃបុគ្គល និងការពង្រឹងការគោរពសិទ្ធិមនុស្ស សេរីភាពជាសារវន្ត និងភាពចម្រុះគ្នានៃមនុស្សជាតិ។

ខ. ការអភិវឌ្ឍបុគ្គលិកលក្ខណៈ ទេពកោសល្យ និងគំនិតច្នៃប្រឌិតរបស់ជនពិការ ក៏ដូចជាលទ្ធភាពខាងកាយសម្បទា និងប្រាជ្ញាស្មារតីឲ្យដល់សក្តានុពលពេញទំហឹងរបស់ពួកគេ។

គ. ជួយឲ្យជនពិការចូលរួមយ៉ាងសកម្មក្នុងសង្គមដោយសេរី។

២- ដើម្បីធ្វើឲ្យសិទ្ធិទាំងនេះបានសម្រេច រដ្ឋភាគីត្រូវធានាថាៈ

ក. ជនពិការមិនត្រូវបានផាត់ចេញពីប្រព័ន្ធអប់រំទូទៅ ដោយសារតែពិការភាពនោះទេ ហើយកុមារពិការមិនត្រូវបានផាត់ចេញពីការអប់រំដែលខានពុំបាន និងឥតបង់ថ្លៃ នៅកម្រិតបឋម ឬមធ្យមសិក្សាដោយសារតែពិការភាព។

ខ. ជនពិការអាចទទួលបានការអប់រំរួមគ្នា មានគុណភាព និងមិនបង់ថ្លៃ នៅកម្រិតបឋម និងមធ្យមសិក្សាដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយ អ្នកផ្សេងទៀតនៅក្នុងសហគមន៍ដែលគេរស់នៅ។

គ. ដំណោះស្រាយសមស្របទៅតាមតម្រូវការ របស់បុគ្គលម្នាក់ៗត្រូវបានផ្តល់។

ឃ. ជនពិការទទួលបានការឧបត្ថម្ភដែលគេត្រូវការ ក្នុងក្របខណ្ឌប្រព័ន្ធអប់រំទូទៅ ដើម្បីជួយសម្រួលពួកគេឲ្យទទួលបានការអប់រំប្រកបដោយប្រសិទ្ធភាព។

ង. វិធានការជួយឧបត្ថម្ភ ជាពិសេសសម្រាប់ជនពិការម្នាក់ៗដ៏មានប្រសិទ្ធភាព ត្រូវបានផ្តល់ឲ្យក្នុងបរិយាកាសដែលបង្កើនការអភិវឌ្ឍសង្គម និងសិក្សាធិការជាអតិបរមាដោយស្របទៅតាមគោលដៅនៃការបញ្ចូលខ្លួនជនពិការ យ៉ាងពេញលេញទៅក្នុងសង្គម។

៣- រដ្ឋភាគីត្រូវជួយជនពិការឲ្យអាចរៀនយកជំនាញអភិវឌ្ឍសង្គម និងបំណិនជីវិត ដើម្បីជួយឲ្យពួកគេចូលរួមបានដោយស្មើភាព និងយ៉ាងពេញលេញក្នុងការអប់រំ និងជាសមាជិកនៃសហគមន៍។ ដើម្បីសម្រេចគោលដៅនេះរដ្ឋភាគីត្រូវចាត់វិធានការសមស្របនានារួមមាន៖

ក. ជួយសម្រួលដល់ការរៀនតាមរបៀបអក្សរស្ទាប អក្សរជំនួស តម្លើង និងជំនួស ព្រមទាំងមធ្យោបាយ និងទម្រង់ផ្សេងៗនៃទំនាក់ទំនង និងជំនាញតម្រង់ទិសនិងការចល័តទី ព្រមទាំងជួយសម្រួលដល់ការគាំទ្រ និងការណែនាំក្រុមជាដៃគូ។

ខ. ជួយសម្រួលដល់ការរៀនភាសាសញ្ញា និងការជំរុញអត្តសញ្ញាណផ្នែកភាសារបស់សហគមន៍ជនពិការ គថ្លង់។

គ. ធានាថាការអប់រំសម្រាប់ជនពិការ ជាពិសេសកុមារដែលពិការភ្នែក គ ថ្លង់ ឬពិការភ្នែកផង គ ថ្លង់ផង ត្រូវបានធ្វើឡើងក្នុងទម្រង់និងភាសា និងមធ្យោបាយទំនាក់ទំនង សម្រាប់ជនពិការម្នាក់ៗដ៏សមស្របបំផុតក្នុងបរិយាកាសបង្កើនការអភិវឌ្ឍសង្គម និងសិក្សាធិការជាអតិបរមា។

៤- ដើម្បីជួយធានាដល់ការសម្រេចឲ្យបាននូវសិទ្ធិនេះ រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានាដើម្បីផ្តល់ការងារដល់គ្រូបង្រៀន រួមទាំងគ្រូពិការដែលមានសមត្ថភាព

ក្នុងការបង្រៀនភាសាសញ្ញា និង/ឬអក្សរស្ទាប និងដើម្បីបណ្តុះបណ្តាលដល់អ្នកជំនាញ និងបុគ្គលិកដែលធ្វើការនៅគ្រប់កម្រិតសិក្សា។ ការបណ្តុះបណ្តាលបែបនេះ ត្រូវដាក់បញ្ចូលការយល់ដឹងអំពីពិការភាព និងការប្រើប្រាស់របៀបនៃការតម្លើង និងជំនួស ព្រមទាំងមធ្យោបាយ និងទម្រង់ផ្សេងៗនៃទំនាក់ទំនងបច្ចេកទេស និងសម្ភារអប់រំសមស្រប ដើម្បីជួយដល់ជនពិការ។

៥- រដ្ឋភាគីត្រូវធានាថា ជនពិការអាចទទួលបានការអប់រំថ្នាក់ឧត្តមសិក្សាជាទូទៅ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំមនុស្សពេញវ័យ និងការសិក្សាពេញមួយជីវិត ដោយគ្មានការរើសអើង និងដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។ ដើម្បីសម្រេចបាននូវគោលដៅនេះ រដ្ឋភាគីត្រូវធានាថា ការសម្របសម្រួលសមស្រប ត្រូវបានផ្តល់ជូនដល់ជនពិការ។

**មាត្រា២៥._**

**សុខភាព**

រដ្ឋភាគីទទួលស្គាល់ថា ជនពិការមានសិទ្ធិក្នុងការទទួលបាននូវនិយាមសុខភាពខ្ពស់បំផុត ដោយគ្មានការរើសអើង ដោយសារតែពិការភាពនោះឡើយ។ រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្រប ដើម្បីធានាដល់ជនពិការឲ្យទទួលបានសេវាកម្មសុខភាពដែលពាក់ព័ន្ធដល់យេនឌ័រ រួមទាំងសុខភាពទាក់ទងនឹងការស្តារលទ្ធភាពពលកម្ម។ ជាពិសេស រដ្ឋភាគីត្រូវ៖

ក. ផ្តល់ដល់ជនពិការនូវឋានៈគុណភាព និងនិយាមដូចគ្នានៃកម្មវិធី និង

សេវាថែទាំសុខភាព ដោយមិនបង់ប្រាក់ ឬតាមតម្លៃមួយសមស្របដូចអ្នកដទៃដែរ រួមទាំងបញ្ហាសុខភាពផ្លូវភេទ និងបន្តពូជ និងកម្មវិធីសុខភាពសាធារណៈជាមូលដ្ឋាន។

ខ. ផ្តល់សេវាកម្មសុខភាពទាំងនេះ ទៅតាមតម្រូវការរបស់ជនពិការ ជាពិសេសព្រោះតែពិការភាពរបស់ពួកគេ រួមទាំងការផ្តល់អត្តសញ្ញាណកម្មពីដំបូង និងការធ្វើអន្តរាគមន៍ឲ្យបានសមរម្យ និងសេវាកម្មដែលបានរៀបចំឡើង ដើម្បីបន្ថយ និងបង្ការពិការភាពបន្ថែមទៀតឲ្យបានជាអប្បបរមា រួមទាំងក្នុងចំណោមកុមារ និងមនុស្សចាស់។

គ. ផ្តល់សេវាកម្មសុខភាពទាំងនេះនៅជិតសហគមន៍របស់ជនពិការបំផុតតាមតែអាចធ្វើទៅបាន រួមទាំងនៅតាមតំបន់ជនបទ។

ឃ. តម្រូវឲ្យអ្នកមានវិជ្ជាជីវៈសុខភាព ផ្តល់ការថែទាំសុខភាពដល់ជនពិការឲ្យមានគុណភាពដូចគ្នានឹងការថែទាំអ្នកដទៃ ដោយឈរលើមូលដ្ឋាននៃការយល់ព្រមដោយសេរី និងដោយបានទទួលព័ត៌មានច្បាស់លាស់ ដោយសារត្រូវបានលើកកម្ពស់ពីការយល់ដឹងអំពីសិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូរ ស្វ័យភាព និងតម្រូវការរបស់ជនពិការតាមរយៈការបណ្តុះបណ្តាល និងការប្រកាសពីនិយាមក្រមសីលធម៌ សម្រាប់ការថែទាំសុខភាពសាធារណៈ និងឯកជន។

ង. ហាមឃាត់ការរើសអើងដល់ជនពិការ ក្នុងការផ្តល់ការធានារ៉ាប់រងសុខភាព និងការធានារ៉ាប់រងជីវិត ដែលការធានារ៉ាប់រងបែបនេះត្រូវបានអនុញ្ញាតដោយច្បាប់ជាតិ ដែលត្រូវបានផ្តល់ឲ្យក្នុងលក្ខណៈមួយដែលយុត្តិធម៌ និងសមហេតុផល។

ច. ទប់ស្កាត់ការបដិសេធ ដែលមានលក្ខណៈរើសអើងចំពោះការផ្តល់ ការថែទាំសុខភាព ឬសេវាកម្មសុខភាព ឬចំណីអាហារ និងសារធាតុរាវដោយសារតែពិការភាព។

## មាត្រា២៦._

## លទ្ធភាពពលកម្ម និងស្តារលទ្ធភាពពលកម្ម

១- រដ្ឋភាគីត្រូវចាត់វិធានការសមស្រប និងមានប្រសិទ្ធភាព រួមទាំងតាមរយៈការជួយគ្នាជាដៃគូដើម្បីឲ្យជនពិការអាចទទួលបាន និងរក្សាបានឯករាជ្យភាពជាអតិបរមា សមត្ថភាពគ្រប់គ្រាន់ខាងកាយសម្បទាផ្លូវចិត្ត សង្គម និងខាងវិជ្ជាជីវៈព្រមទាំងការចូលរួម និងការបញ្ចូលខ្លួនដោយពេញលេញ នៅក្នុងរាល់គ្រប់ទិដ្ឋភាពនៃជីវិត។ ដើម្បីសម្រេចបានគោលដៅនេះ រដ្ឋភាគីត្រូវរៀបចំពង្រឹង និងពង្រីកសេវាកម្ម និងកម្មវិធីលទ្ធភាពពលកម្ម និងស្តារលទ្ធភាពពលកម្មឲ្យបានខ្លាំងក្លា ជាពិសេសក្នុងវិស័យសុខភាព ការងារ ការអប់រំ និងសេវាកម្មសង្គម។ តាមរបៀបបែបនេះសេវាកម្ម និងកម្មវិធីទាំងនេះ៖

ក. ចាប់ផ្តើមនៅដំណាក់កាលដំបូងបំផុតតាមតែអាចធ្វើបាន ហើយផ្អែកទៅលើការវាយតម្លៃពីពហុជំនាញលើតម្រូវការ និងចំណុចខ្លាំងរបស់បុគ្គលម្នាក់ៗ។

ខ. គាំទ្រដល់ការចូលរួម និងការបញ្ចូលខ្លួនទៅក្នុងសហគមន៍ និងគ្រប់ទិដ្ឋភាពនៃសង្គមដែលត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងអាចធ្វើបានដោយជនពិការ នៅជិតសហគមន៍ ដែលពួកគេរស់នៅតាមដែលអាចធ្វើទៅបានរួមទាំងនៅតាមតំបន់ជនបទ។

២- រដ្ឋភាគីត្រូវជំរុញការអភិវឌ្ឍ ការបណ្តុះបណ្តាលបឋម និងការបណ្តុះបណ្តាលបន្តដល់អ្នកមានវិជ្ជាជីវៈ និងបុគ្គលិកធ្វើការខាងសេវាកម្មលទ្ធភាពពលកម្ម និងស្តារលទ្ធភាពពលកម្ម។

៣- រដ្ឋភាគីត្រូវជំរុញលទ្ធភាព ចំណេះដឹង និងការប្រើប្រាស់ឧបករណ៍ និង

បច្ចេកវិទ្យាជំនួយផ្សេងៗ ដែលត្រូវបានរៀបចំឡើងសម្រាប់ជនពិការដោយសារតែពួកគេពាក់ព័ន្ធទៅនឹងលទ្ធភាពពលកម្ម និងស្តារលទ្ធភាពពលកម្ម។

**មាត្រា២៧._**

## ការងារ និង មុខរបរ

១- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការក្នុងការមានការងារធ្វើ ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។ សិទ្ធិនេះរួមទាំងសិទ្ធិមានឱកាសចិញ្ចឹមជីវិត ដោយប្រកបការងារដែលគេអាចជ្រើសរើស ឬ ទទួលយកដោយសេរីលើទីផ្សារការងារ និងបរិយាកាសការងារដែលបើកចំហ ការដាក់បញ្ចូល និងអាចឲ្យជនពិការចូលធ្វើបាន។ រដ្ឋភាគីត្រូវការពារ និងជំរុញដល់ការធ្វើឲ្យសម្រេចបាននូវសិទ្ធិការងារ រួមទាំងសម្រាប់អ្នកទាំងឡាយដែលធ្លាក់ខ្លួនពិការ នៅពេលកំពុងបំពេញការងារ ដោយចាត់វិធានការសមស្រប រួមទាំងវិធានការតាមផ្លូវច្បាប់ដើម្បី៖

ក. ហាមឃាត់ការរើសអើងដោយសារតែពិការភាព ចំពោះគ្រប់បញ្ហាដែលទាក់ទងនឹងរាល់ទម្រង់នៃការងាររួមទាំងលក្ខខណ្ឌនៃការជ្រើសរើស ការជួល និងការបម្រើការងារ ការបន្តការងារ ការអភិវឌ្ឍមុខរបរ និងលក្ខខណ្ឌការងារដែលមានសុវត្ថិភាព និងផាសុកភាព។

ខ. ការពារសិទ្ធិជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃចំពោះលក្ខខណ្ឌការងារត្រឹមត្រូវ និងអនុគ្រោះរួមទាំងឱកាសស្មើគ្នា និងប្រាក់កម្រៃស្មើគ្នាចំពោះការងារដែលមានតម្លៃស្មើគ្នា លក្ខខណ្ឌការងារដែលមានសុវត្ថិភាព និងផាសុកភាព

រួមទាំងកិច្ចការពារពីការឃោឃើ និងការសងជំងឺចិត្ត។

គ. ធានាថាជនពិការអាចអនុវត្តសិទ្ធិបង្កើត សហជីពដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។

ឃ. អាចឲ្យជនពិការទទួលបានដោយប្រសិទ្ធភាពនូវបច្ចេកទេសទូទៅ និងកម្មវិធីណែនាំពីវិជ្ជាជីវៈ សេវាកម្មរកការងារឲ្យធ្វើការបណ្តុះបណ្តាលបន្ត និងវិជ្ជាជីវៈ។

ង. បង្កើនឱកាសមានការងារធ្វើ និងការអភិវឌ្ឍមុខរបរសម្រាប់ជនពិការនៅក្នុងទីផ្សារការងារ ក៏ដូចជាជំនួយ ក្នុងការស្វែងរកការទទួលបានការរក្សានិងការវិលត្រឡប់ចូលបម្រើការងារវិញ។

ច. បង្កើនឱកាសដល់ជនពិការឲ្យមានមុខរបរផ្ទាល់ខ្លួន មានភាពជាសហគ្រិនការបង្កើតសារជីវកម្ម និងចាប់ផ្តើមធ្វើធុរកិច្ចដោយខ្លួនឯង ។

ឆ. ផ្តល់ការងារដល់ជនពិការក្នុងស្ថាប័នសាធារណៈ។

ជ. បង្កើនការងារសម្រាប់ជនពិការ ក្នុងស្ថាប័នឯកជនតាមរយៈវិធានការនិងគោលនយោបាយសមស្រប ដែលអាចរួមមានកម្មវិធីសកម្មភាពជាវិជ្ជមាន កម្មវិធីលើកទឹកចិត្ត និងវិធានការផ្សេងៗទៀត។

ឈ. ធានាឲ្យមានការសម្របសម្រួលសមស្របដល់ជនពិការនៅ ក្នុងកន្លែងធ្វើការ។

ញ.បង្កើនលទ្ធភាពឲ្យជនពិការអាចទទួលបានបទពិសោធន៍ ការងារនៅក្នុងទីផ្សារការងារសេរី។

ដ. ជំរុញការស្តារលទ្ធភាពពលកម្មជំនាញ និងវិជ្ជាជីវៈ ការរក្សាការងារ និងកម្មវិធីនានាដែលជួយឲ្យជនពិការ អាចត្រឡប់ចូលបម្រើការងារវិញ។

២- រដ្ឋភាគីត្រូវធានាថា ជនពិការមិនត្រូវធ្លាក់ទៅក្នុងទាសភាព ឬខ្ញុំកញ្ជះគេ ហើយត្រូវបានគេការពារ ពីការធ្វើពលកម្មដោយបង្ខំ ឬដោយមិនអាចប្រកែកបាន ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។

**មាត្រា២៨._**

## ជីវភាពសមរម្យ និង កិច្ចការពារសង្គម

១- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការ ចំពោះជីវភាពសមរម្យសម្រាប់ខ្លួនគេផ្ទាល់ និងសម្រាប់ក្រុមគ្រួសាររបស់ពួកគេ រួមទាំងការមានអាហារហូបចុកគ្រប់គ្រាន់ មានសំលៀកបំពាក់និងផ្ទះសម្បែងសមរម្យ និងការកែលម្អនូវជីវភាព រស់នៅប្រចាំថ្ងៃ ហើយរដ្ឋភាគីត្រូវចាត់វិធានការជាជំហានៗសមស្របដើម្បីការពារ និងជំរុញដល់ការធ្វើឲ្យបានសម្រេចនូវសិទ្ធិនេះ ដោយគ្មានការរើសអើង និងដោយឈរលើមូលដ្ឋានពិការភាព។

២- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការពីកិច្ចការពារសង្គម និងពីការទទួលបានសិទ្ធិនេះដោយគ្មានការរើសអើងឈរលើមូលដ្ឋានពិការភាព និងត្រូវចាត់វិធានការជាជំហានៗសមស្របដើម្បីការពារ និងជំរុញដល់ការធ្វើឲ្យសម្រេចបាននូវសិទ្ធិនេះរួមទាំងវិធានការដូចខាងក្រោម៖

ក. ធានាដល់ជនពិការឲ្យទទួលបានដោយស្មើភាពនូវសេវាកម្មទឹកស្អាត និងធានាដល់ជនពិការឲ្យទទួលបាននូវសេវាកម្ម គ្រឿងឧបករណ៍ និងជំនួយផ្សេងៗដែល

សមស្រប និងមានតម្លៃសមរម្យសម្រាប់បម្រើសេចក្តីត្រូវការពាក់ព័ន្ធនឹងពិការភាព។

ខ. ធានាដល់ជនពិការ ជាពិសេសស្ត្រី និងកុមារីពិការ និងមនុស្សចាស់ពិការឲ្យទទួលបាននូវកម្មវិធីកាត់បន្ថយភាពក្រីក្រ និងកម្មវិធីការពារសង្គម។

គ. ធានាដល់ជនពិការ និងក្រុមគ្រួសាររបស់គេដែលកំពុងរស់នៅក្នុងស្ថានភាពក្រីក្រ ឲ្យទទួលបាននូវជំនួយឧបត្ថម្ភពីរដ្ឋ តាមរយៈខ្ទង់ចំណាយលើផ្នែកពិការភាព រួមទាំងការបណ្តុះបណ្តាល ការផ្តល់ប្រឹក្សា ជំនួយហិរញ្ញវត្ថុ និងការថែទាំគ្រប់គ្រាន់ក្នុងអំឡុងពេលសម្រាក។

ឃ. ធានាដល់ជនពិការឲ្យទទួលបាននូវកម្មវិធីផ្ទះសម្បែងសាធារណៈ។

ង. ធានាដល់ជនពិការឲ្យទទួលបានដោយស្មើភាពនូវកម្មវិធី និងផលប្រយោជន៍សោធននិវត្តន៍។

## មាត្រា២៩._

## ការចូលរួមក្នុងជីវភាពនយោបាយ និងសាធារណៈ

រដ្ឋភាគីត្រូវធានាដល់ជនពិការពីសិទ្ធិនយោបាយ និងទម្រង់ផ្សេងៗនៃជំនួយដល់ការរស់នៅដែលជនពិការទទួលបាន ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃហើយត្រូវ ៖

ក. ធានាថាជនពិការអាចចូលរួមដោយប្រសិទ្ធភាព និងយ៉ាងពេញលេញក្នុងជីវភាពនយោបាយ និងសាធារណៈដោយផ្ទាល់ ឬ តាមរយៈអ្នកតំណាងដែលត្រូវបានជ្រើសរើសដោយសេរី ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ រួមទាំងសិទ្ធិ

និងទម្រង់ផ្សេងៗនៃជំនួយដល់ការរស់នៅសម្រាប់ជនពិការ ក្នុងការបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោតដោយៈ

(i) ធានាថា នីតិវិធី ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារបោះឆ្នោតមានលក្ខណៈសមស្រប អាចទទួលយកបានងាយយល់ និងងាយប្រើប្រាស់។

(ii) ការពារសិទ្ធិរបស់ជនពិការក្នុងការបោះឆ្នោតដោយសម្ងាត់ និងក្នុងការធ្វើប្រជាមតិជាសាធារណៈ ដោយគ្មានការបំភិតបំភ័យ និងក្នុងការឈរឈ្មោះបោះឆ្នោតដើម្បីចូលកាន់មុខតំណែង និងបំពេញគ្រប់មុខងារសាធារណៈឲ្យមានប្រសិទ្ធភាពនៅគ្រប់ជាន់ថ្នាក់នៃស្ថាប័នរដ្ឋាភិបាល ដោយជួយសម្រួលដល់ការប្រើប្រាស់បច្ចេកវិទ្យា ជំនួយថ្មីៗដែលសមស្រប។

(iii) ធានាដល់ជនពិការនូវការសំដែងឆន្ទៈ ដោយសេរីក្នុងឋានៈជាអ្នកបោះឆ្នោតហើយដើម្បីសម្រេចគោលដៅនេះ ក្នុងករណីចាំបាច់និងតាមសំណើរបស់ជនពិការ អនុញ្ញាតឲ្យមានការជួយក្នុងការបោះឆ្នោតជំនួសដោយអ្នកណាម្នាក់តាមការជ្រើសរើសរបស់ពួកគេ។

ខ. ជំរុញយ៉ាងសកម្មឲ្យមានបរិយាកាសមួយ ដែលជនពិការអាចចូលរួមយ៉ាងពេញលេញ និងជាក់ស្តែងក្នុងដំណើរការកិច្ចការសាធារណៈដោយគ្មានការរើសអើង និងដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ ព្រមទាំងលើកទឹកចិត្តឲ្យពួកគេចូលរួមក្នុងកិច្ចការសាធារណៈរួមមានៈ

(i) ការចូលរួមក្នុងអង្គការក្រៅរដ្ឋាភិបាល និងសមាគមនានាដែលពាក់ព័ន្ធនឹងជីវភាពនយោបាយ និងជីវភាពសាធារណៈរបស់ប្រទេស និងក្នុងសកម្មភាព

និងរដ្ឋបាលរបស់គណបក្សនយោបាយនានា។

(ii) ការបង្កើត និងការចូលរួមក្នុងអង្គការជនពិការនានា ដើម្បីធ្វើជាអ្នកតំណាងជនពិការនៅថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ ថ្នាក់ជាតិ និងនៅលើឆាកអន្តរជាតិ។

**មាត្រា៣០._**

## ការចូលរួមក្នុងវិស័យវប្បធម៌ ការកំសាន្ត ការលំហែ និង កីឡា

១- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការ ក្នុងការចូលរួមក្នុងវិស័យវប្បធម៌ ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ ហើយរដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្របដើម្បីធានាថាជនពិការៈ

ក. ទទួលបានសម្ភារផ្សេងៗ ក្នុងវិស័យវប្បធម៌តាមទ្រង់ទ្រាយដែលគេអាចទទួលបាន។

ខ. ទទួលបានកម្មវិធីតាមទូរទស្សន៍ ភាពយន្ត ល្ខោន និងសកម្មភាពវប្បធម៌ផ្សេងៗក្នុងទ្រង់ទ្រាយដែលគេអាចទទួលបាន។

គ. ចូលដល់ទីកន្លែងសម្រាប់ការសំដែងឬសេវាកម្មវប្បធម៌ ដូចជារោងល្ខោន សារមន្ទីរ រោងភាពយន្ត បណ្ណាល័យ និងសេវាកម្មទេសចរណ៍ ព្រមទាំងតាមលទ្ធភាពដែលអាចធ្វើទៅបាន មានសិទ្ធិចូលដល់បូជនីយស្ថាន និងរមណីយដ្ឋានសំខាន់ៗរបស់វប្បធម៌ជាតិ។

២- រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានា ដើម្បីឲ្យជនពិការអាចមានឱកាសក្នុងការអភិវឌ្ឍ និងប្រើប្រាស់សក្តានុពលខាងបញ្ញា សិល្បៈ និងគំនិតច្នៃប្រឌិត

របស់ខ្លួនមិនត្រឹមតែដើម្បីផលប្រយោជន៍របស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងដើម្បីភាពសម្បូរបែបរបស់សង្គមទៀតផង។

៣- រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្របជាជំហានៗ ដោយអនុលោមតាមច្បាប់អន្តរជាតិដើម្បីធានាថា ច្បាប់ទាំងឡាយដែលការពារកម្មសិទ្ធិបញ្ញា មិនបង្កឧបសគ្គដែលមិនសមហេតុផល ឬរើសអើងអ្វីឡើយដល់ជនពិការក្នុងការទទួលបានសម្ភារក្នុងវិស័យវប្បធម៌។

៤- ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត ជនពិការត្រូវមានសិទ្ធិបានការទទួលស្គាល់ និងការគាំទ្រនៃអត្តសញ្ញាណផ្នែកភាសា និងវប្បធម៌ជាក់លាក់របស់ខ្លួន រួមទាំងភាសាសញ្ញា និងវប្បធម៌ជនពិការគ ថ្លង់។

៥- ក្នុងទស្សនៈជួយឲ្យជនពិការអាចចូលរួម ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃផ្សេងទៀត និងក្នុងសកម្មភាពនានា ផ្នែកកីឡា ការលំហែ និងការកំសាន្ត រដ្ឋភាគីត្រូវចាត់វិធានការសមស្របផ្សេងៗដូចតទៅ៖

ក. ជំរុញ និងលើកស្ទួយការចូលរួមរបស់ជនពិការឲ្យបានខ្លាំងក្លាតាមដែលអាចធ្វើទៅបានក្នុងសកម្មភាពកីឡាជាសាធារណៈនៅគ្រប់កម្រិត។

ខ. ធានាថា ជនពិការមានឱកាសក្នុងការរៀបចំចាត់ចែង អភិវឌ្ឍ និងចូលរួមក្នុងសកម្មភាពកីឡា និងការកំសាន្ត ពិសេសសម្រាប់ជនពិការ ហើយដើម្បីសម្រេចបានគោលដៅនេះ ត្រូវលើកទឹកចិត្តឲ្យមានការផ្តល់ការណែនាំ ការបណ្តុះបណ្តាល និងធនធានសមស្របដោយផ្អែកលើគោលការណ៍ស្មើភាពជាមួយអ្នកដទៃទៀត។

គ. ធានាថា ជនពិការអាចមានទីកន្លែងសម្រាប់លេងកីឡា ការកំសាន្ត

និងទេសចរណ៍។

ឃ. ធានាថា កុមារពិការមានសិទ្ធិទទួលបានស្មើភាពគ្នា ជាមួយកុមារផ្សេងទៀតក្នុងការចូលរួមក្នុងការលេងការលំហែ ការកំសាន្ត និងការសំដែង រួមទាំងសកម្មភាពទាំងឡាយនៅក្នុងកម្មវិធីសាលារៀនផងដែរ។

ង. ធានាថា ជនពិការមានសិទ្ធិទទួលបានសេវាកម្មពីអ្នកទាំងឡាយ ដែលពាក់ព័ន្ធនឹងការរៀបចំសកម្មភាពកីឡា ការលំហែ ទេសចរណ៍ និងការកំសាន្ត។

**មាត្រា៣១._**

## ស្ថិតិ និងការប្រមូលទិន្នន័យ

១- រដ្ឋភាគីទទួលខុសត្រូវប្រមូលព័ត៌មានសមស្រប រួមទាំងទិន្នន័យស្ថិតិ និងស្រាវជ្រាវ ដើម្បីឲ្យជនពិការអាចតាក់តែង និងអនុវត្តគោលនយោបាយ ជំរុញឲ្យអនុសញ្ញានេះមានប្រសិទ្ធភាព។ ដំណើរការប្រមូល និងរក្សាព័ត៌មាននេះត្រូវ ៖

ក. អនុលោមតាមវិធានកិច្ចការពារដែលបានបង្កើតស្របច្បាប់ រួមទាំងច្បាប់ស្តីអំពីការការពារទិន្នន័យ ដើម្បីធានាការសម្ងាត់ និងការគោរពសិទ្ធិឯកជនរបស់ជនពិការ។

ខ. អនុលោមតាមបទដ្ឋានដែលបានទទួលស្គាល់ជាអន្តរជាតិ ដើម្បីការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត និងគោលការណ៍ក្រមសីលធម៌ក្នុងការប្រមូល និងការប្រើប្រាស់ស្ថិតិ។

២- ព័ត៌មានដែលប្រមូលបានស្របតាមមាត្រានេះត្រូវបានចែកចាយ និង

ប្រើប្រាស់តាមការសមស្របដើម្បីជួយវាយតម្លៃការអនុវត្តកាតព្វកិច្ច របស់រដ្ឋភាគីតាមអនុសញ្ញានេះ និងដើម្បីកំណត់ ហើយដោះស្រាយនូវឧបសគ្គនានាដែលជនពិការជួបប្រទះក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន។

៣- រដ្ឋភាគីត្រូវទទួលខុសត្រូវចំពោះការផ្សព្វផ្សាយស្ថិតិទាំងនេះ និងធានាថាស្ថិតិទាំងនេះអាចឲ្យជនពិការនិងអ្នកដទៃទៀតអាចទទួលយកបាន ។

**មាត្រា ៣២._**

**កិច្ចសហប្រតិបត្តិការអន្តរជាតិ**

១- រដ្ឋភាគីទទួលស្គាល់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការនេះ ក្នុងការគាំទ្រដល់ការខិតខំប្រឹងប្រែងថ្នាក់ជាតិចំពោះការធ្វើឲ្យបានសម្រេចនូវគោលបំណង និងទិសដៅរបស់អនុសញ្ញានេះ ហើយនឹងចាត់វិធានការសមស្រប និងមានប្រសិទ្ធភាពចំពោះបញ្ហានេះរវាងនិងក្នុងចំណោមរដ្ឋរួមទាំងដៃគូជាមួយអង្គការអន្តរជាតិនិងតំបន់ដែលពាក់ព័ន្ធ និងសង្គមស៊ីវិលតាមការសមស្រប ជាពិសេសអង្គការជនពិការ។ វិធានការទាំងនេះរួមមានជាអាទិ៍៖

ក. ការធានាថា កិច្ចសហប្រតិបត្តិការអន្តរជាតិ រួមទាំងកម្មវិធីអភិវឌ្ឍអន្តរជាតិនានាត្រូវមានបញ្ចូល ជនពិការ ហើយជនពិការអាចទទួលយកបាន។

ខ. ការសម្របសម្រួល និងការគាំទ្រដល់ការកសាងសមត្ថភាព រួមទាំងតាមរយៈការផ្លាស់ប្តូរ និងការចែករំលែកព័ត៌មាន បទពិសោធន៍ កម្មវិធីបណ្តុះបណ្តាល និងការអនុវត្តប្រកបដោយប្រសិទ្ធភាព។

គ. ការសម្របសម្រួលដល់កិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវ និងការទទួលបានចំណេះដឹង បច្ចេកទេស និងវិទ្យាសាស្ត្រ។

ឃ. ការផ្តល់ជំនួយសេដ្ឋកិច្ច និងបច្ចេកទេសសមស្រប រួមទាំងតាមរយៈការជួយសម្រួលដល់ការទទួលបាន និងការចែករំលែកនូវបច្ចេកវិទ្យាជំនួយ និងទទួលយកបានហើយតាមរយៈការផ្ទេរបច្ចេកវិទ្យា។

២. បទបញ្ញត្តិនៃមាត្រានេះមិនធ្វើឲ្យប៉ះពាល់ដល់កាតព្វកិច្ច របស់រដ្ឋភាគីនីមួយៗ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនតាមអនុសញ្ញានេះឡើយ។

**មាត្រា៣៣._**

## ការអនុវត្ត និងតាមដានត្រួតពិនិត្យថ្នាក់ជាតិ

១- អនុលោមតាមប្រព័ន្ធនៃប្រទេសរបស់ខ្លួន រដ្ឋភាគីត្រូវបង្កើតស្ថាប័នបង្គោលមួយ ឬ ច្រើនក្នុងរដ្ឋាភិបាល សម្រាប់កិច្ចការដែលទាក់ទងនឹងការអនុវត្តអនុសញ្ញានេះ ហើយត្រូវធ្វើការពិចារណាឲ្យបានត្រឹមត្រូវក្នុងការបង្កើត ឬ ការចាត់តាំងយន្តការសម្របសម្រួលមួយនៅក្នុងរដ្ឋាភិបាល ដើម្បីជួយសម្រួលដល់សកម្មភាពដែលពាក់ព័ន្ធក្នុងវិស័យ និងកម្រិតផ្សេងគ្នា។

២- អនុលោមតាមប្រព័ន្ធរដ្ឋបាល និងប្រព័ន្ធច្បាប់របស់ខ្លួន រដ្ឋភាគីត្រូវរក្សាពង្រឹង ចាត់តាំង ឬបង្កើតនូវក្របខណ្ឌការងារមួយនៅក្នុងរដ្ឋភាគី រួមទាំងយន្តការឯករាជ្យមួយ ឬ ច្រើនតាមការសមស្រប ដើម្បីជំរុញការពារ និងតាមដាន ត្រួតពិនិត្យការអនុវត្តអនុសញ្ញានេះ។ នៅពេលបង្កើត និងតែងតាំងយន្តការបែបនេះរដ្ឋភាគីត្រូវយក

ចិត្តទុកដាក់ចំពោះគោលការណ៍ដែលពាក់ព័ន្ធដល់ឋានៈ ឬកម្រិត និងការប្រព្រឹត្តទៅរបស់ស្ថាប័នជាតិនានា ដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។

៣- សង្គមស៊ីវិល ជាពិសេសជនពិការ និងអង្គការតំណាងឲ្យជនពិការ ត្រូវមានទំនាក់ទំនង និងចូលរួមយ៉ាងពេញលេញក្នុងដំណើរការតាមដានត្រួតពិនិត្យ។

**មាត្រា៣៤._**

## គណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការ

១- គណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការមួយ (តទៅនេះហៅថា "គណៈកម្មាធិការ") ត្រូវបានបង្កើតឡើងដើម្បីបំពេញតួនាទីដូចមានចែងនៅក្នុងមាត្រានេះ។

២- នៅពេលដែលអនុសញ្ញានេះចូលជាធរមាន គណៈកម្មាធិការនេះត្រូវមានអ្នកជំនាញការដប់ពីរ (១២)រូប។ បន្ទាប់ពីមានការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកចំនួនហុកសិប (៦០) បន្ថែមទៀតលើអនុសញ្ញានេះ ចំនួនសមាជិករបស់គណៈកម្មាធិការនេះត្រូវបង្កើនចំនួនប្រាំមួយ (៦) រូបទៀត តែទោះយ៉ាងណាត្រូវរក្សាចំនួនសមាជិកអតិបរមាត្រឹមដប់ប្រាំបី(១៨)រូប។

៣-សមាជិកគណៈកម្មាធិការនេះ ត្រូវបម្រើការងារតាមសមត្ថភាពរៀងៗខ្លួន និងត្រូវមានសីលធម៌ខ្ពស់ ព្រមទាំងមានភាពប៉ិនប្រសប់ និងបទពិសោធន៍ដែលត្រូវបានទទួលស្គាល់លើវិស័យដែលគ្របដណ្តប់ដោយអនុសញ្ញានេះ។ នៅពេលតែងតាំងបេក្ខភាពរបស់ខ្លួន រដ្ឋភាគីត្រូវបានអញ្ជើញឲ្យធ្វើការពិចារណាឲ្យបានត្រឹមត្រូវទៅលើបទបញ្ញត្តិដែលមានចែងនៅក្នុងមាត្រា៤ វាក្យខណ្ឌ៣ នៃអនុសញ្ញានេះ។

៤- សមាជិកគណៈកម្មាធិការ ត្រូវបានជ្រើសរើសដោយការបោះឆ្នោតពីរដ្ឋភាគី ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកស្មើភាពតាមលក្ខណៈភូមិសាស្ត្រ ភាពតំណាងនៃទម្រង់ផ្សេងៗរបស់អរិយធម៌ និងប្រព័ន្ធច្បាប់សំខាន់ៗ តុល្យភាពតំណាងយេនឌ័រ និងការចូលរួមពីអ្នកជំនាញការដែលជាជនពិការ។

៥- សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសដោយការបោះឆ្នោតជាសម្ងាត់ពីបញ្ជីឈ្មោះបេក្ខជន ដែលត្រូវបានតែងតាំងដោយរដ្ឋភាគីពីក្នុងចំណោមជនជាតិនៃរដ្ឋភាគីនោះនៅឯកិច្ចប្រជុំនៃសន្និសីទរបស់រដ្ឋភាគី។ ក្នុងកិច្ចប្រជុំទាំងនោះ កូរ៉ុមត្រូវកំណត់ចំនួនពីរភាគបីនៃរដ្ឋភាគី ហើយបេក្ខជនដែលត្រូវបានគេបោះឆ្នោតឲ្យចូលជាសមាជិកនៃគណៈកម្មាធិការនេះ គឺជាអ្នកដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេ និងទទួលបានសំឡេងភាគច្រើនដាច់ខាតពីតំណាងនៃរដ្ឋភាគីដែលមានវត្តមាន និងមានសិទ្ធិបោះឆ្នោត។

៦- ការបោះឆ្នោតដំបូង ត្រូវធ្វើឡើងមិនឲ្យហួសរយៈពេលប្រាំមួយ (៦)ខែក្រោយពីថ្ងៃដែលអនុសញ្ញានេះចូលជាធរមាន។ យ៉ាងហោចបួន(៤)ខែមុនថ្ងៃបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវផ្ញើលិខិតទៅរដ្ឋភាគី ដើម្បីអញ្ជើញរដ្ឋទាំងនោះ ឲ្យដាក់សំណើតែងតាំងបេក្ខភាពរបស់ខ្លួនក្នុងរយៈពេលពីរ(២)ខែ។ បន្ទាប់មក អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីឈ្មោះតាមលំដាប់អក្ខរក្រមនៃបេក្ខជនទាំងអស់ដែលត្រូវបានតែងតាំង ដោយបញ្ជាក់ពីឈ្មោះរដ្ឋភាគីដែលបានតែងតាំងបេក្ខជនទាំងនោះផងហើយត្រូវដាក់ជូនរដ្ឋភាគីនៃអនុសញ្ញានេះវិញ។

៧- សមាជិកគណៈកម្មាធិការ ត្រូវបានជ្រើសតាំងសម្រាប់អណត្តិរយៈពេលបួន(៤)ឆ្នាំ។ សមាជិកទាំងនេះត្រូវមានសិទ្ធិឈរឈ្មោះបោះឆ្នោតសារជាថ្មីបានតែ

ម្តងប៉ុណ្ណោះ។ ប៉ុន្តែអណត្តិរបស់សមាជិកចំនួនប្រាំមួយ (៦)រូប នៃសមាជិកទាំងអស់ដែលត្រូវបានជ្រើសរើសកាលពីការបោះឆ្នោតលើកទីមួយ ត្រូវផុតកំណត់នៅចុងបញ្ចប់នៃរយៈពេលពីរ(២)ឆ្នាំ។ បន្ទាប់ពីការបោះឆ្នោតលើកទីមួយភ្លាម ឈ្មោះរបស់សមាជិកទាំងប្រាំមួយ(៦)រូបនេះត្រូវបានចាប់ឆ្នោត ជ្រើសរើសដោយប្រធាននៃកិច្ចប្រជុំយោងតាមកថា ខ័ណ្ឌទី៥ នៃមាត្រានេះ។

៨- ការបោះឆ្នោតជ្រើសរើសសមាជិកប្រាំមួយ (៦)រូប បន្ថែមនៃគណៈកម្មាធិការ នេះត្រូវធ្វើឡើងក្នុងទម្រង់ផ្សេងៗនៃជំនួយដល់ការរស់នៅនៃការបោះឆ្នោតសាមញ្ញស្របទៅតាមបទបញ្ញត្តិពាក់ព័ន្ធនៃមាត្រានេះ។

៩- ប្រសិនបើសមាជិកណាម្នាក់នៃគណៈកម្មាធិការនេះស្លាប់ ឬ លាលែងពីតំណែង ឬ ប្រកាសថាគាត់មិនអាចបំពេញភារកិច្ចរបស់ខ្លួនបានទៀតទេ ដោយសារមូលហេតុអ្វីក៏ដោយ រដ្ឋភាគីដែលតែងតាំងសមាជិកនោះត្រូវតែងតាំងអ្នកជំនាញការម្នាក់ទៀតដែលមានគុណសម្បត្តិ និងបំពេញបានតាមលក្ខខណ្ឌដែលតម្រូវនៅក្នុងបទបញ្ញត្តិពាក់ព័ន្ធនៃមាត្រានេះ ដើម្បីបន្តបំពេញការងាររហូតដល់ចប់អណត្តិ។

១០- គណៈកម្មាធិការត្រូវបង្កើតបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

១១- អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវផ្តល់បុគ្គលិក និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់ ដើម្បីឲ្យគណៈកម្មាធិការនេះបំពេញតួនាទីប្រកបដោយប្រសិទ្ធភាពតាមអនុសញ្ញានេះ ហើយត្រូវកោះប្រជុំលើកដំបូងរបស់គណៈកម្មាធិការ។

១២- ដោយមានការអនុម័តយល់ព្រម ពីមហាសន្និបាតអង្គការសហប្រជាជាតិ សមាជិកគណៈកម្មាធិការ ដែលត្រូវបានបង្កើតឡើងតាមអនុសញ្ញានេះត្រូវទទួលបាន

ប្រាក់ឧបត្ថម្ភពីប្រភពអង្គការសហប្រជាជាតិតាមបញ្ញត្តិនិងលក្ខខណ្ឌទាំងឡាយ ដូចដែលមហាសន្និបាតបានសម្រេចគិតគូរអំពីសារៈសំខាន់នៃការទទួលខុសត្រូវរបស់គណៈកម្មាធិការនេះ។

១៣- សមាជិកគណៈកម្មាធិការ ត្រូវមានសិទ្ធិប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗ មានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិជាអ្នកជំនាញការដែលកំពុងបំពេញបេសកកម្ម ឲ្យអង្គការសហប្រជាជាតិ ដូចដែលមានចែងក្នុងប្រការពាក់ព័ន្ធទាំងឡាយនៃសន្និសញ្ញាស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ។

**មាត្រា៣៥._**

**របាយការណ៍របស់រដ្ឋភាគី**

១- តាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ រដ្ឋភាគីនីមួយៗត្រូវដាក់របាយការណ៍ លម្អិតស្តីពីការចាត់វិធានការណ៍នានាដើម្បីអនុវត្តកាតព្វកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពតាមអនុសញ្ញានេះ និងស្តីពីវឌ្ឍនភាពដែលសម្រេចបានលើកិច្ចការទាំងនេះក្នុងរយៈពេលពីរ (២)ឆ្នាំបន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន។

២- បន្ទាប់ពីនេះ រដ្ឋភាគីត្រូវដាក់របាយការណ៍បន្តបន្ទាប់របស់ខ្លួនយ៉ាងហោចណាស់រៀងរាល់បួន (៤) ឆ្នាំម្តង និងព័ត៌មានបន្ថែមទៀតនៅពេលណាដែលគណៈកម្មាធិការស្នើសុំ។

៣- គណៈកម្មាធិការត្រូវសម្រេចពីគោលការណ៍ណែនាំ ដែលអាចអនុវត្តបានចំពោះមាតិកានៃរបាយការណ៍។

៤- រដ្ឋភាគីដែលបានដាក់របាយការណ៍ លម្អិតលើកដំបូងទៅគណៈកម្មាធិការ ពុំចាំបាច់លើកឡើងពីព័ត៌មានដដែលៗ ដែលបានផ្តល់កាលពីមុន នៅក្នុងរបាយការណ៍បន្តបន្ទាប់លើកក្រោយទៀតនោះទេ។ នៅពេលរៀបចំធ្វើរបាយការណ៍ជូនគណៈកម្មាធិការ រដ្ឋភាគីត្រូវគិតគូរធ្វើកិច្ចការនេះក្នុងដំណើរការមួយដែលបើកចំហ និងមានតម្លាភាព និងត្រូវផ្តល់ការពិចារណា ឲ្យបានត្រឹមត្រូវទៅតាមបទបញ្ញត្តិដែលមានចែងក្នុងមាត្រា៤ វាក្យខណ្ឌ៣នៃអនុសញ្ញានេះ។

៥- របាយការណ៍អាចបង្ហាញពីកត្តាផ្សេងៗ និងការលំបាកនានាដែលប៉ះពាល់ដល់កម្រិតនៃការបំពេញកាតព្វកិច្ចតាមអនុសញ្ញានេះ។

**មាត្រា៣៦._**

## **ការពិនិត្យពិចារណាលើរបាយការណ៍**

១- របាយការណ៍នីមួយៗ ត្រូវបានពិនិត្យពិចារណាដោយគណៈកម្មាធិការ ដែលត្រូវធ្វើសំណូមពរ និងផ្តល់អនុសាសន៍រួមដល់របាយការណ៍ដែលគណៈកម្មាធិការ យល់ឃើញថាសមស្រប រួចត្រូវបញ្ជូនសំណូមពរ និងអនុសាសន៍ទាំងនេះទៅរដ្ឋភាគីសាមីវិញ។ រដ្ឋភាគីនោះអាចឆ្លើយតបនឹងព័ត៌មានណាមួយដែលខ្លួន ជ្រើសរើសទៅគណៈកម្មាធិការវិញ។ គណៈកម្មាធិការអាចស្នើសុំព័ត៌មានបន្ថែមពីរដ្ឋភាគីដែលពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញានេះ។

២- ប្រសិនបើរដ្ឋភាគីមួយយឺតយ៉ាវខ្លាំង ក្នុងការដាក់ជូនរបាយការណ៍ គណៈកម្មាធិការអាចជូនដំណឹងដល់រដ្ឋភាគីសាមីនោះ អំពីសេចក្តីត្រូវការ ដើម្បីត្រួតពិនិត្យ

ការអនុវត្តអនុសញ្ញានេះនៅក្នុងរដ្ឋភាគីនោះ ដោយផ្អែកលើព័ត៌មានគួរឲ្យទុកចិត្តដែលគណៈកម្មាធិការទទួលបាន ប្រសិនបើរបាយការណ៍ពាក់ព័ន្ធមិនត្រូវបានដាក់ជូនក្នុងរយៈពេលបី (៣)ខែបន្ទាប់ពីការជូនដំណឹង។ គណៈកម្មាធិការត្រូវអញ្ជើញរដ្ឋភាគីសាមីឲ្យចូលរួមក្នុងការត្រួតពិនិត្យបែបនេះ។ ប្រសិនបើរដ្ឋភាគីឆ្លើយតបដោយប្រគល់របាយការណ៍ពាក់ព័ន្ធបទបញ្ញត្តិក្នុងកថាខណ្ឌទី១នៃមាត្រានេះនឹងត្រូវបានអនុវត្ត។

៣-អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវចែករបាយការណ៍ទាំងនោះ ដល់គ្រប់រដ្ឋភាគីទាំងអស់។

៤- រដ្ឋភាគីត្រូវផ្សព្វផ្សាយរបាយការណ៍របស់ខ្លួន ឲ្យបានទូលំទូលាយដល់សាធារណជនក្នុងប្រទេសរបស់ខ្លួន ហើយជួយសម្រួលដល់ការទទួលបានសំណូមពរ និងអនុសាសន៍ទូទៅដែលពាក់ព័ន្ធនឹងរបាយការណ៍នេះ។

៥- គណៈកម្មាធិការត្រូវបញ្ជូនរបាយការណ៍ ដែលបានទទួលពីរដ្ឋភាគីតាមតែខ្លួនយល់ឃើញថាសមស្របទៅទីភ្នាក់ងារជំនាញ ស្ថាប័នមូលនិធិ និងកម្មវិធីនានារបស់អង្គការសហប្រជាជាតិ និងអង្គភាពមានសមត្ថកិច្ចផ្សេងៗទៀត ដើម្បីស្នើសុំ ឬបញ្ជាក់ពីតម្រូវការផ្នែកប្រឹក្សាឬជំនួយបច្ចេកទេស ដូចមាននៅក្នុងរបាយការណ៍ទាំងនោះ ដោយរួមជាមួយនឹងការកត់សម្គាល់ និងអនុសាសន៍របស់គណៈកម្មាធិការចំពោះសំណើ និងសេចក្ដីបញ្ជាក់ទាំងនេះប្រសិនបើមាន។

**មាត្រា៣៧._**

## កិច្ចសហប្រតិបត្តិការរវាងរដ្ឋភាគី និងគណៈកម្មាធិការ

១- រដ្ឋភាគីនីមួយៗត្រូវធ្វើសហប្រតិបត្តិការជាមួយគណៈកម្មាធិការ និងជួយសមាជិកគណៈកម្មាធិការនេះក្នុងការបំពេញការងារក្នុងអណត្តិរបស់ខ្លួន។

២- ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយរដ្ឋភាគី គណៈកម្មាធិការត្រូវគិតពិចារណាឲ្យបានត្រឹមត្រូវដល់វិធី និងមធ្យោបាយនៃការលើកកម្ពស់សមត្ថភាពថ្នាក់ជាតិក្នុងការអនុវត្តអនុសញ្ញានេះ រួមទាំងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា៣៨._**

## ទំនាក់ទំនងរបស់គណៈកម្មាធិការជាមួយស្ថាប័នផ្សេងៗទៀត

ដើម្បីជំរុញឲ្យមានការអនុវត្តអនុសញ្ញានេះ ឲ្យមានប្រសិទ្ធភាព និងដើម្បីលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យដូចមានចែងក្នុងអនុសញ្ញានេះ៖

ក- ទីភ្នាក់ងារជំនាញ និងស្ថាប័ននានារបស់អង្គការសហប្រជាជាតិត្រូវមានអ្នកតំណាង ដើម្បីចូលរួមក្នុងការពិចារណាលើការអនុវត្តនៃបទបញ្ញត្តិរបស់អនុសញ្ញានេះស្ថិតក្នុងវិសាលភាពនៃអណត្តិរបស់ខ្លួន។ គណៈកម្មាធិការអាចកោះអញ្ជើញទីភ្នាក់ងារជំនាញ និងស្ថាប័នមានសមត្ថកិច្ចនានា តាមតែខ្លួនយល់ឃើញថាសមស្រប ដើម្បីផ្តល់ប្រឹក្សាជំនាញពីការអនុវត្តអនុសញ្ញាក្នុងវិស័យ ដែលស្ថិតក្នុងក្របខ័ណ្ឌនៃអណត្តិរៀងៗខ្លួន។ គណៈកម្មាធិការ អាចកោះអញ្ជើញទីភ្នាក់ងារជំនាញ និងស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ឲ្យផ្តល់របាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាក្នុងវិស័យដែលស្ថិតក្នុង

ក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន។

ខ- នៅពេលបំពេញអណត្តិរបស់ខ្លួន គណៈកម្មាធិការត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធដទៃទៀតដែលត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ តាមការសមស្រប ដើម្បីធានាពីភាពស៊ីសង្វាក់គ្នានៃគោលការណ៍ណែនាំសម្រាប់ធ្វើរបាយការណ៍នីមួយៗ សំណូមពរ និងអនុសាសន៍ទូទៅ និងដើម្បីជៀសវាងនូវភាពត្រួតគ្នា និងជាន់ភារកិច្ចគ្នាក្នុងការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា៣៩._**

**របាយការណ៍របស់គណៈកម្មាធិការ**

គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ជារៀងរាល់ពីរ (២)ឆ្នាំម្តងជូនមហាសន្និបាត និងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចរបស់អង្គការសហប្រជាជាតិស្តីពីសកម្មភាពរបស់ខ្លួន ហើយអាចធ្វើសំណូមពរ និងផ្តល់អនុសាសន៍រួម ដោយផ្អែកលើការត្រួតពិនិត្យរបាយការណ៍ និងព័ត៌មានដែលទទួលបានពីរដ្ឋភាគី។ សំណូមពរ និងអនុសាសន៍រួមទាំងនោះត្រូវដាក់បញ្ចូលក្នុងរបាយការណ៍របស់គណៈកម្មាធិការ រួមជាមួយនឹងមតិរបស់រដ្ឋភាគី ប្រសិនបើមាន។

**មាត្រា៤០._**

**សន្និសីទរបស់រដ្ឋភាគី**

១- រដ្ឋភាគីត្រូវជួបប្រជុំគ្នាជាទៀងទាត់ក្នុងសន្និសិទរបស់ខ្លួន ដើម្បីពិនិត្យពិចារណាលើបញ្ហាណាមួយដែលទាក់ទងនឹងការអនុវត្តអនុសញ្ញានេះ។

២-     អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសីទរបស់រដ្ឋភាគីមិនឲ្យហួសរយៈពេលប្រាំមួយ (៦)ខែ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន។ កិច្ចប្រជុំជាបន្តបន្ទាប់ ត្រូវបានកោះប្រជុំដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ រៀងរាល់ពីរ(២)ឆ្នាំម្តង ឬតាមការសម្រេចរបស់សន្និសីទនៃរដ្ឋភាគី។

**មាត្រា៤១._**

**អ្នកតម្កល់ទុកឯកសារ**

អគ្គលេខាធិការអង្គការសហប្រជាជាតិ ជាអ្នករក្សាទុកអនុសញ្ញានេះ។

**មាត្រា៤២._**

**ការចុះហត្ថលេខា**

អនុសញ្ញានេះត្រូវបើកចំហដល់រដ្ឋទាំងអស់ និងអង្គការសមាហរណកម្មនានាថ្នាក់តំបន់ចុះហត្ថលេខា នៅឯទីស្នាក់ការកណ្តាលអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក ត្រឹមថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧ ។

**មាត្រា៤៣._**

**សេចក្តីយល់ព្រមអនុវត្តន៍**

អនុសញ្ញានេះ ត្រូវតែជាកម្មវត្ថុនៃការផ្តល់សច្ចាប័នដោយប្រទេសហត្ថលេខីហើយជាកម្មវត្ថុនៃការបញ្ជាក់ជាផ្លូវការ ដោយអង្គការសមាហរណកម្មហត្ថលេខីថ្នាក់តំបន់នានា។ អនុសញ្ញានេះត្រូវបើកចំហចំពោះការចូលជាសមាជិកដោយប្រទេស ឬអង្គការសមាហរណកម្មតំបន់ណាមួយដែលមិនបានចុះហត្ថលេខាលើអនុសញ្ញានេះ។

**មាត្រា៤៤.**_

## **អង្គការសមាហរណកម្មនានាថ្នាក់តំបន់**

១- ″អង្គការសមាហរណកម្មតំបន់″ មានន័យថាជាអង្គការដែលបង្កើតឡើងដោយរដ្ឋអធិបតេយ្យនៃតំបន់ណាមួយ ដែលរដ្ឋជាសមាជិកនៅក្នុងតំបន់នោះបានប្រគល់សមត្ថកិច្ចឲ្យដោះស្រាយបញ្ហានានាដែលគ្រប់គ្រងដោយអនុសញ្ញានេះ។ អង្គការទាំងនេះត្រូវប្រកាសនៅក្នុងលិខិតុបករណ៍នៃការបញ្ជាក់ជាផ្លូវការ ឬ ការចូលជាសមាជិករបស់ខ្លួនអំពី វិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួនក្នុងការដោះស្រាយបញ្ហានានា ដែលគ្រប់គ្រងដោយអនុសញ្ញានេះ។ បន្ទាប់មកអង្គការទាំងនោះត្រូវជូនដំណឹងដល់អ្នកតម្កល់ទុកឯកសារពីការកែប្រែសំខាន់ៗណាមួយនៅក្នុងវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន។

២-បទបញ្ញត្តិទាំងឡាយដែលយោងដល់ ″រដ្ឋភាគី″ នៅក្នុងអនុសញ្ញានេះត្រូវអនុវត្តចំពោះអង្គការទាំងនេះនៅក្នុងព្រំដែននៃសមត្ថកិច្ចរបស់ខ្លួន។

៣- ចំពោះគោលបំណងនៃមាត្រា៤៥ កថាខ័ណ្ឌទី១ និងមាត្រា៤៧ កថាខ័ណ្ឌទី២ និងទី៣ នៃអនុសញ្ញានេះគឺ លិខិតុបករណ៍ណាក៏ដោយដែលត្រូវតម្កល់ទុកដោយអង្គការសមាហរណកម្មថ្នាក់តំបន់មួយមិនត្រូវបានរាប់បញ្ចូលទេ។

៤- ចំពោះបញ្ហាស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន អង្គការសមាហរណកម្មថ្នាក់តំបន់អាចប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីបោះឆ្នោតនៅឯសន្និសីទនៃរដ្ឋភាគី ដោយមានចំនួនសន្លឹកឆ្នោតស្មើនឹងចំនួននៃប្រទេសជាសមាជិករបស់អង្គការនេះ ដែលជាភាគីនៃអនុសញ្ញា។ អង្គការនេះមិនអាចប្រើសិទ្ធិបោះឆ្នោតរបស់ខ្លួនបានទេ ប្រសិនបើប្រទេសជា

សមាជិករបស់ខ្លួន ប្រើសិទ្ធិបោះឆ្នោតនោះហើយ ឬបញ្ច្រាស់គ្នាមកវិញ។

**មាត្រា៤៥._**

**ការចូលជាធរមាន**

១- អនុសញ្ញានេះត្រូវចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីមានការតម្កល់ទុកលិខិតុបករណ៍ទី ២០នៃការផ្តល់សច្ចាប័ន ឬ ការចូលជាសមាជិក។

២- ចំពោះរដ្ឋ ឬអង្គការសមាហរណកម្មថ្នាក់តំបន់នីមួយៗដែលនឹងផ្តល់សច្ចាប័ន ការបញ្ជាក់ជាផ្លូវការ ឬការចូលជាសមាជិកនៃអនុសញ្ញានេះ ក្រោយពីការតម្កល់ទុកលិខិតុបករណ៍ទី២០នោះ អនុសញ្ញានេះត្រូវចូលជា ធរមាននៅថ្ងៃទី៣០ចំពោះរដ្ឋនោះក្រោយពីការតម្កល់ទុកលិខិតុបករណ៍របស់ខ្លួន។

**មាត្រា៤៦._**

**ការដាក់លក្ខខណ្ឌ**

១- ការដាក់លក្ខខណ្ឌដែលមិនស្របនឹងកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញានេះមិនត្រូវបានអនុញ្ញាតឡើយ។

២-ការដាក់លក្ខខណ្ឌដូចខាងលើនេះអាចត្រូវបានដកវិញនៅពេលណាក៏បាន។

**មាត្រា៤៧._**

**ការធ្វើវិសោធនកម្ម**

១- រដ្ឋភាគីណាក៏ដោយអាចស្នើសុំធ្វើវិសោធនកម្ម អនុសញ្ញានេះបានរួចដាក់សំណើនោះជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការអង្គការសហ

ប្រជាជាតិត្រូវជូនព័ត៌មានស្តីពីសំណើធ្វើ វិសោធនកម្មទាំងឡាយទៅរដ្ឋភាគី ដោយស្នើសុំឲ្យរដ្ឋទាំងនោះ បញ្ជាក់ថាតើខ្លួនគាំទ្រឲ្យមានសន្និសីទនៃបណ្តារដ្ឋភាគីទៅលើគោលបំណងនៃការពិចារណា និងការសម្រេចលើសំណើទាំងនោះឬទេ។ ក្នុងរយៈពេលបួន (៤)ខែគិតចាប់ពីថ្ងៃដែលជូនដំណឹងនោះមក ក្នុងករណីដែលរដ្ឋភាគីយ៉ាងតិចមួយភាគបីគាំទ្រ ឲ្យមានសន្និសីទបែបនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសីទនេះក្រោមកិច្ចឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ ការធ្វើវិសោធនកម្មណាមួយដែលអនុម័តដោយសំឡេងភាគច្រើនពីរភាគបីនៃរដ្ឋភាគីដែលមានវត្តមាន និងមានសិទ្ធិបោះឆ្នោត ត្រូវបានអគ្គលេខាធិការអង្គការសហប្រជាជាតិដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិសម្រាប់ការអនុម័តយល់ព្រម រួចហើយជូនទៅគ្រប់រដ្ឋភាគីសម្រាប់ការទទួលយល់ព្រម។

២- ការធ្វើវិសោធនកម្មដែលបានយល់ព្រម និងអនុម័តអនុលោមទៅតាមកថាខ័ណ្ឌទី១នៃមាត្រានេះ ត្រូវចូលជាធរមាននៅថ្ងៃទី៣០បន្ទាប់ពីមានចំនួនលិខិតុបករណ៍នៃការទទួលយល់ព្រមត្រូវបានតម្កល់ទុក រហូតដល់ពីរភាគបីនៃរដ្ឋភាគី នៅកាលបរិច្ឆេទធ្វើការអនុម័តលើវិសោធនកម្មនេះ។ បន្ទាប់មកវិសោធនកម្មនេះត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីណាក៏ដោយនៅថ្ងៃទី៣០ ក្រោយពីការតម្កល់ទុកលិខិតុបករណ៍នៃការទទួលយល់ព្រមរបស់ខ្លួន។ វិសោធនកម្មអនុវត្តបានតែចំពោះរដ្ឋភាគីណាដែលបានទទួលយល់ព្រមលើការធ្វើវិសោធនកម្មនោះតែប៉ុណ្ណោះ។

៣- ប្រសិនបើការធ្វើវិសោធនកម្មនេះ ត្រូវបានសម្រេចដោយសន្និសីទនៃរដ្ឋភាគី ដោយការយល់ព្រមជាឯកច្ឆ័ន្ទការធ្វើវិសោធនកម្មដែលបានយល់ព្រម និងអនុម័ត

ដោយអនុលោមតាមកថាខ័ណ្ឌទី១នៃមាត្រានេះ ពាក់ព័ន្ធទាំងស្រុងទៅនឹងមាត្រា៣៤ ៣៨ ៣៩ និង៤០ ត្រូវចូលជាធរមានសម្រាប់គ្រប់រដ្ឋភាគី នៅថ្ងៃទី៣០បន្ទាប់ពីមានលិខិតុបករណ៍មួយចំនួននៃការទទួលយល់ព្រមត្រូវបានតម្កល់ទុក រហូតដល់ពីរភាគបីនៃរដ្ឋភាគី នៅថ្ងៃធ្វើការអនុម័តលើវិសោធនកម្មនេះ។

**មាត្រា៤៨._**

## ការដកខ្លួនចេញពីអនុសញ្ញា

រដ្ឋភាគីមួយអាចដកខ្លួនចេញពីអនុសញ្ញានេះបាន ដោយជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ការដកខ្លួននេះត្រូវមានប្រសិទ្ធភាព១ឆ្នាំក្រោយបន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបានសេចក្តីជូនដំណឹងនោះ។

**មាត្រា៤៩._**

## ទម្រង់ងាយស្រួលប្រើប្រាស់

អត្ថបទនៃអនុសញ្ញានេះ ត្រូវតែធ្វើឡើងក្នុងទម្រង់ដែលមានលក្ខណៈងាយស្រួលប្រើប្រាស់។

**មាត្រា៥០._**

## អត្ថបទសក្ខីភាព

អត្ថបទនៃអនុសញ្ញានេះ មានជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដែលមានតម្លៃជាសក្ខីភាពស្មើគ្នា៕

**អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាសកម្មភាពជនពិការ**
**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក
ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ (១១៥)
Phone : +855-23-727-428
Fax : +855-23-727-426
E-mail : dac.org.k
Website: www.dac.org.kh

បោះពុម្ពលើកទី១
ចំនួន 500ក្បាល
ចែកជូនដោយឥតគិតថ្លៃ